# សេចក្តីថ្លែងការណ៍
# របស់អង្គការមិនមែនរដ្ឋាភិបាល
# ស្តីពីឆ្នាំទីមួយនៃការអនុវត្ត
# យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS)

## ខែ មិនា ឆ្នាំ ២០០៤

បោះពុម្ពផ្សាយដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ខែ មីនា ឆ្នាំ ២០០៤

ខ្លឹមសារនៃឯកសារនេះអាចដកស្រង់ ឬបោះពុម្ពសារឡើងវិញ សំរាប់គោលបំណងអភិវឌ្ឍ ប៉ុន្តែសូមមេត្តាបញ្ជាក់ប្រភពសំរង់ពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ។

# មាតិកា


បញ្ជីឈ្មោះពាក្យបំព្រួញ ៥

**សេចក្ដីសង្ខេប ៧**

**១. សេចក្ដីផ្ដើម ១១**

១.១. គោលបំណងនៃរបាយការណ៍ ១២

១.២. ដំណើរការរៀបចំសេចក្ដីថ្លែងការណ៍នេះ ១២

**២. ការចូលរួម និង ភាពជាដៃគូ ១៣**

២.១. តួនាទីរបស់រដ្ឋាភិបាល ១៣

២.២. តួនាទីរបស់ម្ចាស់ជំនួយ ១៤

២.៣ តួនាទីរបស់ NGOs និង សង្គមស៊ីវិល ១៥

២.៤ តួនាទីរបស់ផ្នែកឯកជន ១៧

**៣. ការរីកចំរើន បញ្ហា និងអនុសាសន៍ ១៩**

៣.១ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអនុវត្តថវិកា ១៩

៣.១.១ ការរីកចំរើន ១៩

៣.១.២ បញ្ហា ២០

៣.១.៣. អនុសាសន៍ ២១

៣.២. ការលើកកំពស់ជីវភាពជនបទ ២៣

៣.២.១ ការរីកចំរើន ២៣

៣.២.២ បញ្ហា ២៣

៣.២.៣ អនុសាសន៍ ២៥

៣.៣. ការពង្រីកកាលានុវត្តភាពការងារ ២៧

៣.៣.១. ការរីកចំរើន ២៧

៣.៣.២. បញ្ហា ២៧

៣.៣.៣. អនុសាសន៍ ៣០

៣.៤. ការធ្វើអោយប្រសើរឡើងនូវសមត្ថភាព ៣២

៣.៤.១. ការរីកចំរើន ៣២

៣.៤.២. បញ្ហា ៣២

៣.៤.៣. អនុសាសន៍ ៣៤

៣.៥. ការពង្រឹងស្ថាប័ននិងលើកកំពស់អភិបាលកិច្ច ៣៦

៣.៥.១. ការរីកចំរើន ៣៦

៣.៥.២. បញ្ហា ៣៦

៣.៥.៣. អនុសាសន៍ ៣៨

៣.៦.ការកាត់បន្ថយភាពងាយរងគ្រោះ ៤០

៣.៦.១. ការរីកចំរើន ៤០

៣.៦.២. បញ្ហា ៤១

៣.៦.៣. អនុសាសន៍ ៤៣

# បញ្ជីឈ្មោះពាក្យបំព្រួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា |
| CG | ក្រុមពិគ្រោះយោបល់ |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា |
| COM | ទីស្តីការគណៈរដ្ឋមន្ត្រី |
| EPZ | តំបន់កែឆ្នៃសំរាប់នាំចេញ |
| EU | សហគមន៍អឺរ៉ុប |
| FDI | វិនិយោគទុនបរទេសផ្ទាល់ |
| GMAC | សមាគមរោងចក្រកាត់ដេរកម្ពុជា |
| GSCSD | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| MDGs | គោលដៅសហសវត្សរ៍ |
| MEDiCAM | អង្គការសមាជិករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលសកម្មក្នុងផ្នែកសុខាភិបាល នៅកម្ពុជា |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MOE | ក្រសួងបរិស្ថាន |
| MOI | ក្រសួងមហាផ្ទៃ |
| MOSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា |
| MOWVA | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NA | សភាជាតិ |
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| PAP | ផែនការសកម្មភាពអាទិភាព |
| PMATU | អង្គភាពតាមដានភាពក្រីក្រ និងបច្ចេកទេស |

| | |
|---|---|
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| WB | ធនាគារពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# សេចក្តីសង្ខេប

សហគមន៍ NGO សូមកោតសរសើរចំពោះកិច្ចការរបស់ RGC ក្នុងការរៀបចំឡើងនូវ NPRS និងសូមស្វាគមន៍ ឱកាសរួមចំណែកក្នុងការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំលើកទីមួយ។ សហគមន៍ NGO សូមរំលឹកឡើងជាថ្មីម្តងទៀត នូវការគាំទ្ររបស់ខ្លួន ចំពោះការអនុវត្ត NPRS របស់រដ្ឋាភិបាល។ NGOs ក៏មានបំណងបន្តកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងជាមួយម្ចាស់ជំនួយដើម្បីបន្តបង្កើត អនុវត្ត និងតាមដានត្រួតពិនិត្យ នូវលទ្ធផលរបស់ NPRS សំដៅ សំរេចអោយបាននូវបច្ច័យយ៉ាងពិតប្រាកដ លើការកាត់បន្ថយភាពក្រីក្រ។

NGOs មានក្តីសោមនស្សរីករាយដោយបានមើលឃើញ មន្ត្រីរដ្ឋាភិបាលដែលប្តូរផ្តាច់ខិតខំប្រឹងប្រែងចំណាយកំលាំងពលំយ៉ាងច្រើន ចំពោះការកសាងឯកសារ NPRS និងរបាយការណ៍ស្តីពីការរីកចំរើន នៅពេលក្រោយមកទៀត ព្រមទាំងមានឆន្ទៈទទួលយកនូវគំនិតយោបល់ពី NGOs។ NPRS នាំទៅដល់ការចែករំលែកបន្ថែមទៀត នូវផែនការរវាងបណ្តាក្រសួងផ្សេងៗរបស់រដ្ឋាភិបាល និង NGOs ហើយក្នុងន័យនេះ ត្រូវបានគេមើលឃើញថា ជាការវិវត្តន៍មួយជំហានទៅមុខប្រកបដោយវិជ្ជមាន។

ទន្ទឹមនឹងនេះ ដំណើរការ NPRS បានដាក់សំពាធទៅលើសមត្ថភាពដែលមានកំរិត និងនាំទៅដល់ភាពជាន់គ្នានៃការធ្វើរបាយការណ៍ដែលមានស្រាប់ និងដំណើរការនៃការធ្វើផែនការ។ ភាពម្ចាស់ការនៃ NPRS ទាំងលើឯកសារ និងដំណើរការ ហាក់ដូចជាស្ថិតនៅតែក្នុងក្រុមមន្ត្រីមួយចំនួនតូចប៉ុណ្ណោះ។ តាមរបៀបជាប្រព័ន្ធមួយនៃការធ្វើផែនការ និងរបាយការណ៍ ដែលមានការកំណត់ពីខាងក្រៅ ដំណើរការ NPRS គឺជាដំណើរការមួយនៃការធ្វើរបាយការណ៍ទៅម្ចាស់ជំនួយ ជាជាងប្រព័ន្ធនៃការធ្វើផែនការជាតិ។ NGOs ស្នើអោយរដ្ឋាភិបាលកំណត់នូវដំណើរការនៃការធ្វើផែនការ ដែលសមស្របបំផុតទៅនឹងស្ថានប័ននានា និងបរិការណ៍វប្បធម៌របស់កម្ពុជា។ ដំណើរការនៃការកសាងផែនការដែលមានស្រាប់ ទាមទារអោយមានការវិភាគ ដើម្បីកំណត់ពីឧបសគ្គ និងដំណោះស្រាយ។ ម្ចាស់ជំនួយត្រូវកែតំរូវនូវការរំពឹងទុករបស់ខ្លួន ដើម្បីអនុញ្ញាតអោយមានការវិវត្តនៃដំណើរការធ្វើផែនការមួយ ដែលដឹកនាំដោយកម្ពុជាខ្លួនឯង។ RGC ត្រូវដឹកនាំដំណើរការដោយខ្លួនឯង ក្នុងការកំណត់អាទិភាពគំរោងជាច្រើន ដែលបានលើកឡើងនៅក្នុង NPRS ដោយមានការពិភាក្សាជាមួយសង្គមស៊ីវិល និងការគាំទ្របច្ចេកទេសពីម្ចាស់ជំនួយ។

ទន្ទឹមនឹងជំរុញអោយរដ្ឋាភិបាលអង្គុយនៅក្នុង " កៅអីអ្នកបើកបរ" ម្ចាស់ជំនួយមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកផ្តល់នូវចក្ខុវិស័យរយៈពេលវែង សំរាប់កិច្ចអភិវឌ្ឍនៅកម្ពុជា។ ខ្លឹមសារជាសារវ័ន្តចំពោះចក្ខុវិស័យនេះ គឺការសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) នៅឆ្នាំ ២០១៥។ ម្ចាស់ជំនួយត្រូវពិចារណាអំពីកំរិតនៃធនធានដែលបានមកពីបរទេស ដើម្បីសំរេចអោយបាននូវចក្ខុវិស័យនេះ និងធ្វើការសន្យាសំរាប់រយៈពេល ១០ ឆ្នាំ ដើម្បីផ្តល់ជំនួយក្នុងកំរិតមួយដែលចាំបាច់។ ការសន្យារយៈពេលវែងនេះ ត្រូវតែមានដាក់លក្ខខណ្ឌ ជាមួយ

រដ្ឋាភិបាល ក្នុងការចាត់វិធានការតាមការចាំបាច់ ដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ទាំងជំនួយក្រៅប្រទេស និងធនធានផ្ទាល់ខ្លួន។ ជំនួយត្រូវតែផ្តល់ទៅតាមដំណាក់កាលសមស្រប ដើម្បីឆ្លើយតបអោយបានយ៉ាងប្រត្យក្ស ទៅនឹងឧបសគ្គផ្នែកសមត្ថភាព។ កំណែទំរង់ប្រកបដោយប្រសិទ្ធភាពចំពោះអភិបាលកិច្ច កំណែទំរង់រដ្ឋបាល កំណែទំរង់តុលាការ និងវិធានការតឹងរ៉ឹងប្រឆាំងនឹងអំពើពុករលួយ គឺជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន សំរាប់ការចែកចាយជំនួយទៅក្នុងផ្នែកជាច្រើនប្រកបដោយប្រសិទ្ធភាព។ ត្រូវកំណត់ និងឯកភាពទៅលើបទដ្ឋានគោល (benchmark) ដែលមានលក្ខណៈប្រាកដនិយម ក្នុងចំណោមម្ចាស់ជំនួយទាំងអស់ ហើយបទដ្ឋាននេះត្រូវមានការតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព រីឯផលវិបាកផ្សេងៗដែលនាំអោយយើងមិនអាចសំរេចបានទៅតាមបទដ្ឋាន ត្រូវចង្អុលបង្ហាញអោយបានច្បាស់លាស់។

សហគមន៍ NGO ស្វាគមន៍នូវការបញ្ចូលសហគមន៍ខ្លួន ទៅក្នុងដំណើរការនៃការរួមចំណែកចំពោះ NPRS និងការវាយតំលៃពីការរីកចំរើនរបស់ NPRS។ សហគមន៍ NGO ព្យាយាមយ៉ាងខ្លាំងក្លាដើម្បីចូលរួមនៅក្នុងដំណើរការនេះក្នុងកាយវិការជាវិជ្ជមាន ដោយផ្តល់វិភាគទានសំដៅគាំទ្រដល់អ្នកក្រ និងប្រកបដោយបទពិសោធន៍ ទាំងចំពោះការពិភាក្សាជុំវិញការកាត់បន្ថយភាពក្រីក្រ និងតាមរយៈសកម្មភាពកាត់បន្ថយភាពក្រីក្ររបស់គេផ្ទាល់។ បញ្ហានៃការចូលរួមរបស់សង្គមស៊ីវិលអោយកាន់តែធំធេងជាងមុន នៅក្នុងដំណើរការ NPRS គឺជាការលំបាក ដោយហេតុថាមានការរីកចំរើនតិចតួចនៅក្នុងវិស័យនេះ។ យើងអាចភ្ជាប់នូវទំនាក់ទំនងអោយបានច្រើនជាងមុន រវាងដំណើរការនៃការធ្វើផែនការថ្នាក់ជាតិ និងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនៅថ្នាក់វិមជ្ឈការមូលដ្ឋាន ដើម្បីធានានូវលំហូរពតិមានពីថ្នាក់ក្រោមទៅថ្នាក់លើ។

ជាថ្មីម្តងទៀត សហគមន៍ NGO សូមស្នើអោយមានការវិភាគពីផលប៉ះពាល់លើសង្គម និងភាពក្រីក្រទាំងស្រុង ដែលបណ្តាលមកពីគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និងពាណិជ្ជកម្ម ដើម្បីអោយឧបករណ៍នយោបាយដែលផ្តោតគោលដៅចំពោះអ្នកក្រខ្លាំងបំផុតនោះ ត្រូវបានបញ្ចូលនៅក្នុងគោលនយោបាយទាំងនោះ។ សហគមន៍ NGO ជំរុញអោយ RGC បន្តធ្វើកំណែទំរង់ប្រព័ន្ធបើកផ្តល់ថវិកា និងពង្រឹងប្រព័ន្ធត្រួតពិនិត្យខាងក្នុង និងខាងក្រៅទៅលើថវិកា ដូចជាតាមរយៈប្រព័ន្ធសវនកម្មដ៏មានប្រសិទ្ធភាព ការបង្កើនតម្លាភាព និងការពង្រឹងសមត្ថភាពស្ថាប័ន។ ចាំបាច់ត្រូវផ្តល់ធនធានហិរញ្ញវត្ថុទៅអោយក្រសួងនានាដោយគ្មានភាពលំអៀងផ្នែកនយោបាយ។

រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ត្រូវធ្វើឡើងដើម្បីរៀបចំឡើងវិញ នូវតារាងបំណុលដែលជំពាក់សហរដ្ឋអាមេរិក និងរុស្ស៊ី។ សហរដ្ឋអាមេរិក អាចពិចារណាការលើកលែងបំណុលក្នុងកំរិតខ្លះ ជាផ្នែកមួយនៃជំនួយរបស់ខ្លួនមកកម្ពុជា។ សភាជាតិគួរពិភាក្សាអំពីកំរិតនៃប្រាក់កំចី ដែលត្រូវទទួលយកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដោយគិតគូរពិចារណាទាំងលើតំរូវការរបស់ប្រទេស និងសមត្ថភាពរបស់ខ្លួនដើម្បីស្រូបទាញយកជំនួយ ដើម្បីកំណត់នូវកំរិតនៃការសងបំណុល នៅក្នុងថវិកានាពេលអនាគត។

ទន្ទឹមនឹង NGOs ឯកភាពលើទិដ្ឋភាពជាច្រើន នៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល មានវិស័យពីរបីដែល NGO ជឿជាក់ថា ការគិតពិចារណាអំពីយុទ្ធសាស្ត្រឡើងវិញ នឹងមានសារៈប្រយោជន៍។ កត្តានេះឈានចេញមកពីប្រការដែលថា ក្រុមជនងាយរងគ្រោះជាច្រើននៅក្នុងសង្គមកម្ពុជា នឹងកាន់តែទទួលទុក្ខលំបាក ដែលបណ្តាលមកពីលទ្ធផលនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ចលឿន ប្រសិនបើគំរូវការរបស់គេ មិនត្រូវបានយកលើកមកពិចារណា អោយបានពេញលេញទេនោះ :

- បើទោះបីជាកោតសរសើរពីកាលានុវត្តភាព ដែលមាននៅក្នុងពាណិជ្ជកម្មសេរីក៏ដោយ សហគមន៍ NGO មានក្តីបារម្ភថា សហគ្រាសធុនតូច និងធុនមធ្យម ជាពិសេសកសិករតូចតាចនៅកម្ពុជា មិនទាន់មានសមត្ថភាព ធ្វើការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិបានឡើយ។ ការបាត់បង់ ទីផ្សារក្នុងស្រុក ដោយសារកំណើននៃការប្រកួតប្រជែងពីអន្តរជាតិ អាចបង្កើនភាពក្រីក្រនៅក្នុង ស្រទាប់ភាគច្រើននៃប្រជាជនកម្ពុជា ប្រសិនបើសេរីភាវូបនីយកម្មពាណិជ្ជកម្មមិនត្រូវបានកំណត់ ដំណាក់កាលអោយបានសមស្រប និងមិនបង្កើនសមត្ថភាពអោយលឿនទេនោះ។
- ផលវិបាកច្រាសនៃតំបន់កែច្នៃសំរាប់នាំចេញ ត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធជាច្រើន។ លើឆាកអន្តរជាតិ EPZs បង្ហាញនូវនិន្នាការឆ្ពោះទៅបង្កើតវិនិយោគទុន ផលិតកម្ម និងទីកដីដែល ស្រូបទាញផលចំណេញដោយមានទំនាក់ទំនងត្រលប់វិញតិចតួច ឬក៏វិនិយោគទុនឡើងវិញ នៅក្នុងសេដ្ឋកិច្ចប្រទេសម្ចាស់ផ្ទះ។ NGO មានការព្រួយបារម្ភពីលទ្ធភាពនៃការធ្លាក់ចុះការងារ និងបទដ្ឋាន បរិស្ថាន នៅក្នុងតំបន់ទាំងនេះ ដែលជាការបាត់បង់កាលានុវត្តភាព ចំណូលសារពើពន្ធ និងការបង្កើន វិសមភាពចំពោះសេដ្ឋកិច្ចដែលមានស្រាប់។
- ការបង្កើតអោយមានចំការកសិកម្ម និងសម្បទានធំៗ មិនទំនងជានឹងជួយដល់កសិករធុនមធ្យម និងអាចកាត់បន្ថយនូវការទទួលបានដីធ្លី និងធនធានធម្មជាតិរបស់សហគមន៍នៅជនបទ។ ផ្ទុយទៅវិញ សហគមន៍ NGO សូមស្នើអោយមានការផ្តោតលើការពង្រីកសេវាប្រពលវប្បកម្ម ចំពោះកសិករតូចតាច គឺជាការផ្គត់ផ្គង់ឧបករណ៍ខ្នាតតូចសំរាប់បំរើអោយធារាសាស្ត្រ ដែលថែទាំ ដោយអ្នកប្រើប្រាស់ និងការប្រើប្រាស់នូវវិធីសាស្ត្រដែលប្រើដើមទុនតិច សំរាប់បង្កើនផលិតផលកសិផល។
- ភាពសំបូរបែបនៃប្រព័ន្ធជីវៈចំរុះនៅកម្ពុជា និងជីវភាពរស់នៅរបស់សហគមន៍ជនបទជាច្រើន គួរត្រូវបានទ្រទ្រង់អោយកាន់តែប្រសើរជាងមុន តាមរយៈការបង្កើនការទ្រទ្រង់ដល់សហគមន៍ព្រៃឈើ ជាពិសេសគឺចៀរជ័រឈើនៅក្នុងព្រៃសំខាន់ៗ ជាជាងការកាប់ព្រៃឈើនៅកម្ពុជា ដើម្បីដាំដំណាំ កសិផលយកប្រាក់ និងដាំកៅស៊ូ។ សេដ្ឋកិច្ចដែលបានមកពីចំការកៅស៊ូ គួរតែចោទសួរអោយបានល្អិតល្អន់។

- ផលប្រយោជន៍របស់ជនពិការ ត្រូវរំលេចអោយបានកាន់តែច្បាស់នៅក្នុង NPRS ។ ត្រូវមានផែនការរយៈពេលវែង សំរាប់ផ្នែកពិការភាព ដែលធានានូវការសន្យាផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់ សំរាប់សេវា នីតិសម្បទា និងដោះស្រាយទាំងពិការភាពរាងកាយ និងស្មារតី ។
- ស្ថានភាពរបស់ជនជាតិភាគតិច ត្រូវលើកឡើងអោយបានពេញលេញនៅក្នុង NPRS ។ ត្រូវលើកឡើងជាកំណត់អំពីសហគមន៍នៅតំបន់ខ្ពង់រាប ហើយ RGC ត្រូវគិតគូរពិចារណាពីតំរូវការរបស់ជនជាតិភាគតិចវៀតណាម និងជនជាតិចាម ជុំវិញការកាត់បន្ថយភាពក្រីក្រ ។

នៅទីបញ្ចប់ គេមិនត្រូវមើលស្រាលដល់សារៈសំខាន់នៃស្ថេរភាពនយោបាយ ក្នុងការធានាស្ថេរភាពសេដ្ឋកិច្ច ការរីកចំរើនក្នុងវិស័យកំណែទំរង់ និងការកាត់បន្ថយភាពក្រីក្រឡើយ ។ ប្រជាជនកម្ពុជាអនុវត្តនូវករណីយកិច្ចជាពលរដ្ឋក្នុងការបោះឆ្នោតក្នុងចំនួនយ៉ាងច្រើន នៅក្នុងការបោះឆ្នោតជាសាកល នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣។ ពេលនេះ គឺអាស្រ័យលើអ្នកនយោបាយ ក្នុងការធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ សំដៅបង្កើតរដ្ឋាភិបាលថ្មី និងសភាជាតិ ស្របតាមរដ្ឋធម្មនុញ្ញ និងសំដៅបង្កើតរបៀបវារៈនយោបាយមួយ ដែលនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា ។

ជាចុងក្រោយ តំលៃរបស់ NPRS ស្ថិតនៅលើការអនុវត្តយុទ្ធសាស្រ្តនេះ ជាជាងមានតែនៅក្នុងឯកសារ ។ អ្នកក្រីក្រនៅកម្ពុជា ចង់ឃើញភាពប្រសើរឡើងនៅក្នុងជីវភាពរបស់គេយ៉ាងពិតប្រាកដ ដែលជាលទ្ធផលនៃគំរោងអភិវឌ្ឍន៍នានា។ អ្នកពាក់ព័ន្ធទាំងអស់ មានការទទួលខុសត្រូវច្បាស់លាស់មួយ គឺត្រូវសហការគ្នាដើម្បីធានាអោយមានការអភិវឌ្ឍន៍ជានិរន្តរ៍សំដៅជួយដល់អ្នកក្រ ដែលអាចនឹងសំរេចបាន ។

# ១. សេចក្តីផ្តើម

នៅក្នុងសន្និសីទលើកទី ២ សំរាប់តំបន់អាស៊ីអគ្នេយ៍ និងប៉ាស៊ីហ្វិក ស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានរៀបចំឡើងនៅក្រុងភ្នំពេញ កាលពីខែ តុលា ឆ្នាំ ២០០៣ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា " ការកាត់បន្ថយភាពក្រីក្រ ជាអ្នកកំណត់ និងដឹកនាំនូវសារៈសំខាន់ ខ្លឹមសារ បេះដូង និងព្រលឹងនៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលទាំងស្រុង "[១]។ ជាពិសេស ការ-អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ត្រូវបានសង្កត់ធ្ងន់ថា ជា " អាទិភាពគន្លឹះ " របស់រដ្ឋាភិបាល។ សេចក្តីថ្លែងការណ៍នានាសំដៅពង្រឹងការប្តេជ្ញាចិត្តរបស់ RGC ចំពោះការកាត់បន្ថយភាពក្រីក្រ ត្រូវបានទទួលស្វាគមន៍ ដើម្បីកំណត់ NPRS ធ្វើជាធាតុសារវ័ន្តនៃសកម្មភាពរបស់រដ្ឋាភិបាល។ នៅពេលនេះ សេចក្តីថ្លែងការណ៍ទាំងនេះ ត្រូវតែទ្រទ្រង់ដោយសកម្មភាពជាក់ស្តែង ពីសំណាក់ក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់ RGC។

RGC នឹងត្រូវទទួលបាននូវការអបអរសាទរ ចំពោះកិច្ចការរបស់ខ្លួន ក្នុងការរៀបចំ និងបញ្ចប់នូវយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រលើកទី ១ សំរាប់កម្ពុជា (NPRS)។ សហគមន៍ NGO ជឿជាក់ថា តំលៃនៃយុទ្ធសាស្ត្របែបនេះ នឹងស្ថិតនៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាព និងការតាមដានត្រួតពិនិត្យ។

រហូតមកដល់ពេលនេះ មានរយៈពេលមួយឆ្នាំហើយ ចាប់តាំងពី RGC បានផ្សព្វផ្សាយ NPRS។ នៅពេលនេះ អ្នកពាក់ព័ន្ធទាំងអស់ប្រឈមមុខនឹងឱកាសនៃការវាយតំលៃការអនុវត្តយុទ្ធសាស្ត្រនេះ ក្នុងរយៈកាលដំបូង។ ក្នុងការវាយតំលៃនេះ NGOs មានបំណងផ្តល់នូវគំនិត យោបល់ពាក់ព័ន្ធការរីកចំរើនរបស់ NPRS និងស្នើឡើងនូវ អាទិភាព និងបញ្ហាទាំងឡាយ ដែលគួរដោះស្រាយ ក្នុងកំឡុងពេលអនុវត្តខាងមុខ។

ក្នុងការអនុវត្តសំដៅកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈសកម្មភាពរបស់ខ្លួន NGOs មានតួនាទីសំខាន់។ បទពិសោធន៍ជាក់ស្តែងទាំងនេះ ជាប្រយោជន៍ដល់ NGOs ក្នុងការវាយតំលៃ NPRS ការអនុវត្ត និងការកសាងនៅពេលអនាគត។ សេចក្តីថ្លែការណ៍របស់ NGO លើកនេះ លើកឡើងនូវគនិតសំខាន់៧បំផុតមួយចំនួន ដែល NGO នៅកម្ពុជាយល់ឃើញថាជាកង្វល់ដ៏ធំក្នុងពេលបច្ចុប្បន្ននេះ។

យើងគួរកត់សំគាល់ថា អ្នកពាក់ព័ន្ធទាំងអស់ ហាក់ដូចជាសន្និដ្ឋានថា RGC ត្រូវកំណត់អាទិភាពនានាអោយកាន់តែច្បាស់ សំដៅដោះស្រាយភាពក្រីក្រ។ NPRS មិនបានផ្តល់នូវរបៀបវារៈណាមួយដែលមានប្រសិទ្ធភាព សំរាប់ចាត់វិធានការឡើយ។ នេះបង្ហាញអោយឃើញតាមរយៈ គំរោងនានាដែលត្រូវចំណាយថវិកា នៅក្នុងម៉ាទ្រីសនៃផែនការសកម្មភាព កើនឡើងរហូតដល់ ៥.២ ពាន់លានដុល្លារ ដែលខ្ពស់ឆ្ងាយពីធនធាន ឬសមត្ថភាពដែលមាន។ ការខកខានមិនបានកំណត់អាទិភាពគំរោងជាច្រើន នៅក្នុងម៉ាទ្រីសនឹងអនុញ្ញាតអោយម្ចាស់ជំនួយ ជ្រើសរើសគំរោងតាមគេចង់បាន។ វានឹងនាំអោយម្ចាស់ជំនួយក្លាយជាអ្នកគ្រប់គ្រង នៅពេល ដែលឈានដល់ការកំណត់អាទិភាពការងារអភិវឌ្ឍន៍។

ក្នុងការគិតគូរពីអាទិភាព សំរាប់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ជាការចាំបាច់ត្រូវមើលអោយហួសពី NPRS និងយកមកគិតគូរនូវគោលដៅ និងអាទិភាពនានាដែលបានឯកភាពជាទូទៅ ដូចជាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងការប្តេជាញចិត្តរបស់កម្ពុជា ទៅតាមកតិកាសញ្ញា និងអនុសញ្ញានានារបស់អង្គការសហប្រជាជាតិ រួម

---

[1] ដកស្រង់ពី Cambodia Daily ចុះថ្ងៃទី ១៧.១០.០៣ ទំព័រ ១, ១៤

មានកតិកាសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុសញ្ញាស្ដីពីការលុបបំបាត់ការរើសអើងចំពោះស្ត្រី និង អនុសញ្ញាស្ដីពីសិទ្ធិកុមារ ។ ការប្ដេជ្ញាចិត្តទាំងនេះ ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌ NPRS ។

## ១.១. គោលបំណងនៃរបាយការណ៍

សេចក្ដីថ្លែងការណ៍នេះ ដាក់ជូន RGC និងម្ចាស់ជំនួយពាក់ព័ន្ធនឹងរបាយការណ៍អំពីការរីកចំរើនប្រចាំឆ្នាំលើកទី ១ របស់ RGC ស្ដីពីការអនុវត្ត NPRS ។

គោលបំណងរបស់សហគមន៍ NGO ក្នុងការកសាងសេចក្ដីថ្លែងការណ៍នេះឡើង គឺដើម្បីផ្ដល់នូវចំលើយរបស់ NGO ចំពោះ NPRS ។ RGC ប្ដេជ្ញាចិត្តចំពោះការតាមដានត្រួតពិនិត្យដោយមានការចូលរួម ហើយសហគមន៍ NGO សូមចូលរួមចំណែកចំពោះការត្រួតពិនិត្យនេះ ។

## ១.២. ដំណើរការរៀបចំសេចក្ដីថ្លែងការណ៍នេះ

ក្នុងដំណើរកសាងសេចក្ដីថ្លែងការណ៍នេះ NGOs បានចែករំលែកពតិមាន និងបទពិសោធន៍នានាអំពីការអនុវត្ត NPRS នៅឆ្នាំទីមួយ ។ កិច្ចប្រជុំជាច្រើនត្រូវបានរៀបចំឡើង និងបានស្ទាបស្ទង់គំនិតយោបល់ផ្សេងៗរបស់ NGOs ។

ទន្ទឹមនឹងនេះ ក្រុម NGO តាមផ្នែកបានរៀបចំឯកសារតាមផ្នែក ហើយសមាសធាតុគន្លឹះដែលមានលើកឡើង នៅក្នុងឯកសារតាមផ្នែកទាំងនេះ ត្រូវបានបញ្ចូលនៅក្នុងសេចក្ដីថ្លែងការណ៍នេះ ។ កំរងឯកសារតាមផ្នែក[២] នឹងត្រូវបោះពុម្ពផ្សាយដោយឡែក ពីសេចក្ដីថ្លែងការណ៍នេះ ហើយនឹងផ្ដល់ជាពតិមានដល់ដំណើរធ្វើរបាយការណ៍ NPRS ព្រមទាំងជាឯកសារសំរាប់ប្រើប្រាស់ នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្ដីពីកម្ពុជាលើកក្រោយ ។

សហគមន៍ NGO សូមស្វាគមន៍នូវរាល់ការវាយតំលៃណាមួយចំពោះសេចក្ដីថ្លែងការណ៍នេះ ។

[2] *ឯកសារតាមផ្នែក និងតាមបញ្ហារបស់ NGO ស្ដីពីការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ ២០០៤ ដែលបោះពុម្ពផ្សាយដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ខែ មីនា ២០០៤*

# ២. ការចូលរួម និង ភាពជាដៃគូ

សហគមន៍ NGO អបអរសាទរ RGC ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការចែករំលែកពត៌មាន និងប្រមូលនូវរាល់មតិយោបល់ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ចំពោះការរៀបចំ NPRS។ គេសង្ឃឹមថា យុទ្ធវិធីដោយមានការចូលរួមនេះ នឹងនៅតែបន្ត។ ការចែករំលែកពត៌មាន និងគំនិតយោបល់ដែលនាំទៅដល់ការកំណត់អាទិភាព ចំពោះយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនឹងមានសារៈសំខាន់ ប្រសិនបើ NPRS មិនគ្រាន់តែជារបាយការណ៍ ដែលសរសេរឡើង ដើម្បីគ្រាន់តែទទួលផលប្រយោជន៍ពីម្ចាស់ជំនួយ។ បទពិសោធន៍ និងជំនាញរបស់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវចែករំលែក និងពិនិត្យពិច័យ ដើម្បីប្រើប្រាស់ហិរញ្ញវត្ថុសំរាប់អភិវឌ្ឍន៍នៅកម្ពុជា អោយបានត្រឹមត្រូវបំផុត។

## ២.១. តួនាទីរបស់រដ្ឋាភិបាល

ស្ថាប័ន Bretton Woods បានផ្តល់សញ្ញាថា ដំណើរការ NPRS គឺជាការចាប់ផ្តើមទំព័រថ្មីមួយ ក្នុងការធ្វើផែនការ និងរបាយការណ៍ដោយកម្ពុជាផ្ទាល់ សំរាប់ការកាត់បន្ថយភាពក្រីក្រ។ NGOs មានក្តីសោមនស្សរីករាយដោយបានឃើញមន្ត្រីរាជការដែលមានការប្តូរផ្តាច់ ខិតខំយ៉ាងច្រើនចំពោះឯកសារ NPRS និងការធ្វើរបាយការណ៍ស្តីពីការរីកចំរើនជាបន្តបន្ទាប់ ព្រមទាំងមានឆន្ទៈទទួលយកនូវគំនិតយោបល់ពី NGOs។ NPRS កាន់តែនាំទៅដល់ការចែករំលែកផែនការនានា រវាងក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល និង NGOs ហើយនេះ ត្រូវបានចាត់ទុកថាជាការបោះជំហានទៅមុខជាវិជ្ជមាន។

ទន្ទឹមនឹងនេះ ដំណើរការ NPRS ក៏ដាក់សំពាធលើសមត្ថភាពដែលមានកំរិតស្រាប់ និងនាំអោយមានការជាន់គ្នា នៃដំណើរការធ្វើរបាយការណ៍ និងផែនការដែលមានស្រាប់។ ភាពម្ចាស់ការរបស់ NPRS ទាំងឯកសារ និងដំណើរការ ហាក់ដូចជាស្ថិតនៅក្នុងដៃមន្ត្រីរដ្ឋាភិបាលមួយក្រុម។ តាមរបៀបជាប្រព័ន្ធនៃការធ្វើរបាយការណ៍ និងផែនការ ដែលមានការកំណត់ពីខាងក្រៅ NPRS ហាក់ដូចជាគ្រាន់តែជា ដំណើរការមួយនៃការធ្វើរបាយការណ៍ទៅម្ចាស់ជំនួយ ជាជាងប្រព័ន្ធមួយនៃការធ្វើផែនការជាតិ។ ប្រព័ន្ធនេះបានដោះស្រាយតិចតួចចំពោះភាពទន់ខ្សោយដែលមានសព្វថ្ងៃ។ ភាពទន់ខ្សោយទាំងនេះ រួមមាន:

- កំសោយលើទំនាក់ទំនងរវាងការធ្វើផែនការ ការរៀបចំថវិកា ការចំណាយ និង ការផ្តល់សេវាជាក់ស្តែង។
- របៀបវារៈមួយដែលគ្រប់គ្រងដោយអាទិភាព និងកម្មវិធីនានារបស់ម្ចាស់ជំនួយ
- ខ្វះការសំរបសំរួលគ្នា រវាងក្រសួង ស្ថាប័ននានា។
- សមត្ថភាពដែលមានកំរិតរបស់រដ្ឋាភិបាល ដោយសារកង្វះកំណែទំរង់រដ្ឋបាល។

NGOs ចែករំលែកនូវកង្វល់របស់ខ្លួន ជាមួយម្ចាស់ជំនួយ អំពីកង្វះភាពច្បាស់លាស់នៃតួនាទីរបស់ក្រុមធ្វើរបាយការណ៍ស្តីពីការរីកចំរើន នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអន្តរក្រសួងសំរាប់អភិវឌ្ឍសង្គម (GSCD) ក្រោមការដឹកនាំរបស់ក្រសួងផែនការ។ NGOs សង្កេតឃើញថា កង្វះភាពច្បាស់លាស់ដូច្នេះ ពេលខ្លះអាចនឹងកាន់តែមានភាពធ្ងន់ធ្ងរដោយសារសកម្មភាពរបស់ម្ចាស់ជំនួយ។ ទោះបីជាយ៉ាងនេះក្តី ក៏នេះមិនមែនជាបញ្ហាដែលបន្ទុចបង្អាក់ ការខិតខំប្រឹងប្រែង ឬតំលៃដែលបានផ្តល់ជូនមន្ត្រីនៅក្នុងស្ថាប័នទាំងនេះឡើយ ហើយរដ្ឋាភិបាលគួរតែមានការប្តេជ្ញាចិត្ត

កាន់តែខ្ពស់ ដោយរួមទាំងផែនការនានា ដើម្បីពង្រឹងសមត្ថភាព និង អាជ្ញាធរនៃស្ថាប័នដែលទទួលខុសត្រូវ។ គេបានទទួលស្គាល់ថា GSCSD បានកសាងនូវកំលាំងជំរុញ និងជំនាញ ក្នុងកំឡុងពេលនៃការរៀបចំ NPRS ដំបូង មិនគួរអោយបាត់បង់ទៅវិញឡើយ ក្នុងខណៈពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតែងតែផ្តល់នូវការវិភាគយ៉ាងមធ្យ័ត អំពីសេដ្ឋកិច្ច និងថវិកា។ យុទ្ធសាស្ត្រអន្តរក្រសួង រួមជាមួយនឹងភាពម្ចាស់ការ និងការចូលរួមដោយក្រសួងខ្សែពាក់ព័ន្ធ មានសារៈសំខាន់ ក្នុងការបង្កើតនូវទំនាក់ទំនងរវាងការធ្វើរបាយការណ៍ NPRS និងការអនុវត្តន៍ជាក់ស្តែង។

ដំណើរការ NPRS ត្រូវកំណត់អាទិភាពថវិកាជាតិ និងការគាំទ្ររបស់ម្ចាស់ជំនួយ។ ដូចដែលលើកឡើងនៅក្នុងសេចក្តីផ្តើម បញ្ហាចំបងរបស់ NPRS គឺថា យុទ្ធសាស្ត្រនេះបានបញ្ចូលនូវផែនការសកម្មភាពមួយ ដែលមានតំលៃថ្លៃជាងពី ៤-៥ ដង នៃតំលៃដែលរដ្ឋាភិបាលសង្ឃឹមថានឹងអាចទទួលបាន ឬគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ នៅឆ្នាំ ២00៣ ក្រសួងផែនការបានស្នើសុំអោយបណ្តាក្រសួងនានា ផ្តល់ពតិមានអំពីគំរោង និងផែនការនានា ដែលពាក់ព័ន្ធនឹង NPRS ដើម្បីអោយក្រសួងអាចជួយកំណត់អាទិភាពគំរោង និងតំរង់ទិសម៉ាទ្រីស NPRS ទៅក្នុងកម្មវិធីវិនិយោគសាធារណៈ។ សំណើសុំជំនួយបច្ចេកទេសក្នុងការកំណត់អាទិភាពទាំងនេះ មិនទទួលបានការឆ្លើយតបឡើយ។

NGOs ជឿថាបាយការណ៍ស្តីពីការរីកចំរើនរបស់ NPRS មិនត្រូវគ្រាន់តែជាឯកសារ ដែលសរសេរឡើងដើម្បីបំពេញចិត្តធនាគារពិភពលោក និង IMF ឬម្ចាស់ជំនួយដទៃទៀតឡើយ។ របាយការណ៍ស្តីពីការរីកចំរើន ត្រូវតែសរសេរពីកម្ពុជា ផ្តល់មតិយោបល់ និងការណែនាំដល់មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការអភិវឌ្ឍន៍ និងផ្តល់ពតិមានដល់អ្នកកសាងគោលនយោបាយ សមាជិកសភា និងសាធារណៈជន អំពីការរីកចំរើនក្នុងការកាត់បន្ថយភាពក្រីក្រ។ អ្នកដែលនឹងមើលរបាយការណ៍នេះជាងគេ អាចមានមន្ត្រីនៅតាមក្រសួង សមាជិកសភា ភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកកាសែត។ របាយ-ការណ៍ស្តីពីការរីកចំរើន ត្រូវតែមានជាភាសាខ្មែរអោយហើយស្រេច សំរាប់សាធារណៈជនទូទៅ។

NGOs ស្នើអោយរដ្ឋាភិបាលដំណើរការធ្វើផែនការដែលសមស្របបំផុតទៅនឹងបរិការណ៍ស្ថាប័ន និងវប្បធមិរបស់កម្ពុជា។ ដំណើរការនៃការធ្វើផែនការបច្ចុប្បន្ន ត្រូវធ្វើការវិភាគ ដើម្បីកំណត់នូវឧបសគ្គ និង រកដំណោះស្រាយ។ ម្ចាស់ជំនួយត្រូវកែតំរូវក្តីរំពឹងទុករបស់ខ្លួន ដើម្បីអនុញ្ញាតអោយមានការវិវត្តន៍មួយ នៃដំណើរការធ្វើផែនការ ដែលដឹកនាំដោយកម្ពុជា។

## ២.២. តួនាទីរបស់ម្ចាស់ជំនួយ

ទន្ទឹមនឹងជំរុញអោយរដ្ឋាភិបាល ទៅអង្គុយនៅក្នុង "កៅអីអ្នកបើកបរ" ម្ចាស់ជំនួយមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវចក្ខុវិស័យយូរអង្វែង សំរាប់កិច្ចអភិវឌ្ឍន៍នៅកម្ពុជា។ សារៈសំខាន់ចំពោះចក្ខុវិស័យនេះ គឺជាការសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) នៅដំណាច់ឆ្នាំ ២០១៥។ ម្ចាស់ជំនួយត្រូវគិតគូរពិចារណាពីជំនួយដែលបានមកពីបរទេសចាំបាច់ សំរាប់សំរេចអោយបាននូវចក្ខុវិស័យនេះ និងធ្វើការសន្យារយៈ ពេល ១០ ឆ្នាំ ដើម្បីផ្តល់ជំនួយក្នុងកំរិតមួយដែលចាំបាច់។

ការសន្យារយៈពេលវែងនេះ ត្រូវតែមានលក្ខខណ្ឌចំពោះ RGC សំដៅចាត់វិធានការសមស្រប ដើម្បីប្រើប្រាស់ជំនួយបរទេស និងធនធានផ្ទាល់របស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ ជំនួយត្រូវផ្តល់ទៅតាមដំណាក់កាលកំណត់ ដើម្បីឆ្លើយតបប្រកបដោយប្រត្យក្ស ទៅនឹងឧបសគ្គ

ផ្នែកសមត្ថភាព។ កំណែទំរង់ប្រកបដោយប្រសិទ្ធភាពចំពោះអភិបាលកិច្ច កំណែទំរង់រដ្ឋបាល កំណែទំរង់យុត្តិធមិ និង វិធានការតឹងរ៉ឹងប្រឆាំងនឹងអំពើពុករលួយ មានសារៈសំខាន់មិនអាចខ្វះបាន សំរាប់ការបែងចែកជំនួយទៅតាមផ្នែកជាច្រើនប្រកបដោយប្រសិទ្ធភាព។ ត្រូវកំណត់នូវបទដ្ឋានគោល (benchmark) មួយដែលអាចជឿបាន និងត្រូវឯកភាពពីម្ចាស់ជំនួយទាំងអស់។ បទដ្ឋានគោលនេះត្រូវធ្វើការតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ហើយផលវិបាកនានាដែល ធ្វើអោយយើងមិនអាចសំរេចបានទៅតាមបទដ្ឋាននេះ ត្រូវលើកឡើងអោយបានច្បាស់លាស់។ បទដ្ឋាននានាមុននេះ ចាំបាច់ត្រូវធ្វើការវាយតំលៃនៅមុនពេលធ្វើការសន្យា។

ការលើកឡើងនូវចក្ខុវិស័យ និងការសន្យាជាសមូសហភាព ដើម្បីសំរេចអោយបាននូវគោលដៅសហសវត្សរ៍ តំរូវអោយមានការសំរបសំរួលពីសំណាក់ម្ចាស់ជំនួយអោយបានកាន់តែប្រសើរជាងមុន។ ការកែប្រែក្រុមការងារបច្ចុប្បន្ន ដើម្បីសំរួលដល់ការសំរបសំរួលរវាងម្ចាស់ជំនួយ-រដ្ឋាភិបាល និង NGO គឺជាសញ្ញាវិជ្ជមានមួយដែលអាចអនុវត្តបាន។

ជាសំខាន់នោះ ម្ចាស់ជំនួយត្រូវយល់ដឹងអោយបានពេញលេញនូវដំណើរការនៃការធ្វើផែនការបច្ចុប្បន្ន ដើម្បីអាចអោយគេយោង NPRS ទៅនឹងការធ្វើសេចក្តីសំរេចចិត្តជាក់ស្តែង។ ពេលនេះហាក់ដូចជាឆាប់ពេកក្នុងការដាក់ចេញនូវដំណើរការនៃការធ្វើផែនការមួយថ្មី លើកលែងតែមានការតំរូវ។ សហគមន៍ NGOs មានក្តីបារម្ភថា មួយផ្នែកធំនៃកាផ្តោតការយកចិត្តទុកដាក់ចំពោះការរៀបចំ NPRS គឺជាកិច្ចខំប្រឹងប្រែងដើម្បីរៀបចំជាឯកសារសារមួយ សំរាប់ការប្រើប្រាស់របស់ម្ចាស់ជំនួយ។ វាជាការគួរអោយសោកស្តាយដែលឯកសារ NPRS ត្រូវបានរៀបចំឡើងជាភាសាអង់គ្លេសដោយទើបតែមានការបកប្រែ នៅដំណាក់កាលចុងក្រោយប៉ុណ្ណោះ។ យុទ្ធវិធីនេះក៏កើតមានដដែល នៅពេលរៀបចំរបាយការណ៍ស្តីពីការរីចំរើន។ យើងមើលឃើញច្បាស់ថាវិធីសាស្ត្ររបៀបនេះ រារាំងដល់លទ្ធភាពចូលរួមរបស់ប្រជាជនកម្ពុជាមួយភាគធំ ទាំងមន្ត្រីរដ្ឋាភិបាល និងសង្គមស៊ីវិល។

## ២.៣ តួនាទីរបស់ NGOs និង សង្គមស៊ីវិល

សហគមន៍ NGO ស្វាគមន៍នូវការបញ្ចូលសហគមខ្លួន ទៅក្នុងដំណើរការនៃការរួមចំណែក ចំពោះ NPRS និងវាយតំលៃការរីកចំរើន។ សហគមន៍ខិតខំប្រឹងប្រែងយ៉ាងខ្លាំដើម្បីចូលរួមក្នុងដំណើរការនេះ ប្រកបដោយកាយវិការជាវិជ្ជមាន ដោយរួមវិភាគទានសំដៅជួយដល់អ្នកក្រ និង ប្រកបដោយបទពិសោធន៍ ទាំងនៅក្នុងការពិភាក្សាជុំវិញការកាត់បន្ថយភាពក្រីក្រ និងតាមរយៈសកម្មភាពកាត់បន្ថយភាពក្រីក្ររបស់ខ្លួនផ្ទាល់។

NGOs ដែលជាស្ថាប័នអភិវឌ្ឍន៍ អាចរួមវិភាគ-ទានយ៉ាងច្រើន ចំពោះផែនការកាត់បន្ថយភាពក្រីក្រ។ តាមរយៈការចែករំលែកនូវការពិនិត្យសង្កេត និងការសន្និដ្ឋាន ដែលទទួលបានមកពីបទពិសោធន៍ក្នុងការអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន NGOs ធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកក្រ និងក្រុមដែលងាយរងគ្រោះ ហេតុនេះ ខ្លួនមានតួនាទីយ៉ាងសមស្រប ក្នុងការពាំនាំនូវសេចក្តីត្រូវការពីក្រុមទាំងនេះមកអ្នកធ្វើសេចក្តីសំរេចចិត្ត ។

នៅកម្ពុជា ឧបករណ៍ដ៏មានសារៈសំខាន់ដើម្បីសំដែងនូវការសង្កេត និងកង្វល់របស់ NGO គឺសេចក្តីថ្លែងការណ៍ប្រចាំឆ្នាំរបស់ NGO។ នៅក្នុងឆ្នាំ ១៩៩៣ នៅពេលដែល NGO ចូលរួមនៅក្នុងកិច្ចប្រជុំលើកទីមួយ របស់គណៈកម្មាធិការអន្តរជាតិ សំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញ (ICORC) NGOs អាចផ្តល់នូវពុទ្ធិយ៉ាងសំបូរ

បែប ដោយផ្អែកតាមបទពិសោធន៍របស់ខ្លួន អស់រយៈពេល ១៣ ឆ្នាំ នៅកម្ពុជា។ ចាប់ពីពេលនោះមក NGO បានចូលរួមរាល់កិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជា ហើយនៅរៀងរាល់ឆ្នាំ តែងតែបានបង្ហាញនូវសេចក្តីថ្លែងការណ៍ពីស្ថានមួយ ស្តីពីបញ្ហា និងអនុសាសន៍របស់ NGOs សំរាប់កិច្ចអភិវឌ្ឍន៍នៅកម្ពុជា។

NGOs ក៏បានចូលរួមនៅក្នុងក្រុមការងារម្ចាស់ជំនួយរដ្ឋាភិបាលជាច្រើនដែរ។ តែទោះជាយ៉ាងនេះក្តី នៅក្នុងពេលកន្លងមក ក្រុមការងារទាំងនេះ មិនបានបញ្ចូល NGO ឡើយ ក្នុងខណៈដែលក្រុមផ្សេងទៀតមិនបានបញ្ចូលរដ្ឋាភិបាល។ គេយល់ថាក្រុមការងារថ្មី នឹងបញ្ចូល ទាំងរដ្ឋាភិបាល ម្ចាស់ជំនួយ និង NGO។ ការតំណាងរបស់ NGO នៅក្នុងកិច្ចប្រជុំ CG និងក្រុម ការងារទាំងឡាយ គឺជាការសំរបសំរួលគ្នាយ៉ាងមានប្រសិទ្ធភាព រវាងអង្គការសមាជិក NGO ធំ និងប្រព័ន្ធក្រុម NGO តាមផ្នែកក្រៅផ្លូវការ។

NGOs ក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយបណ្តាក្រសួងក្នុងផ្នែកជាច្រើន ដែលផ្តល់ឱកាសសំរាប់ការផ្តល់មតិយោបល់ដោយផ្ទាល់ ចំពោះការពិភាក្សាពីនយោបាយតាមផ្នែក។ ឧទាហរណ៍ សមាគមអង្គការមិនមែនរដ្ឋាភិបាល MEDiCAM ដែលប្រតិបត្តិការនៅក្នុងវិស័យសុខាភិបាល សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល ក្នុងខណៈដែល NGO Education Partnership សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ។ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់របស់ NGO មានការិយាល័យទំនាក់ទំនង NGO មួយ នៅក្នុងក្រសួងមហាផ្ទៃ។

RGC ត្រូវគិតគូរពិចារណាពង្រីកការពិភាក្សា ដើម្បីបញ្ចូលក្រុមផ្សេងៗទៀត នៅក្នុងសង្គមស៊ីវិល។ ក្រុមដែលមានទស្សនវិស័យ និងតំរូវការជាក់ស្តែងចំពោះការកាត់បន្ថយភាពក្រីក្រ ដូចជា ជនជាតិភាគតិច សហជីពកម្មករ និងសមាគមកសិករ គួរតែផ្តល់ឱកាសជូនពួកគាត់ ដើម្បីសំដែងយោបល់។

បញ្ហានៃការចូលរួមរបស់សង្គមស៊ីវិល អោយកាន់តែទូលំទូលាយនៅក្នុងដំណើរការ NPRS គឺជាប្រការមួយលំបាក ដោយហេតុថា មានការរីកចំរើនតិចតួចនៅក្នុងវិស័យនេះ។ បញ្ហានៅត្រង់ថា តើមានវិធីណាដើម្បីបញ្ចូលក្តីបារម្ភរបស់ប្រជាជនកម្ពុជាទូទៅ ទៅក្នុងការធ្វើផែនការ ការ-អនុវត្តន៍ និងការតាមដានត្រួតពិនិត្យ NPRS។ ខាងក្រោមនេះ គឺជាសំណើថា តើត្រូវធ្វើយ៉ាងណា ដើម្បីធ្វើអោយប្រសើរឡើង នូវការចូលរួមរបស់សង្គមស៊ីវិលទាំងអស់ ទៅអនាគត :

- សភាជាតិមានតួនាទីដ៏សំខាន់ ក្នុងការតំណាងអ្នកទាំងនេះ។ ក្នុងការតំណាងនេះ សភាមិនត្រឹមតែមានតួនាទីធ្វើច្បាប់ និងអនុម័តផែនការប៉ុណ្ណោះទេ ប៉ុន្តែសភាក៏ត្រូវចំណាយពេលវេលាបន្ថែមទៀត ស្តាប់រាស្ត្រក្នុងមណ្ឌលរបស់ខ្លួន ដើម្បីអោយខ្លួនអាចតំណាងអ្នកទាំងនោះកាន់តែត្រឹមត្រូវ។ បច្ចុប្បន្ននេះ ម្ចាស់ជំនួយតិចតួចប៉ុណ្ណោះដែលជួយកសាងសមត្ថភាពសភា ហើយភាគច្រើន នៅក្នុងដំណើរការ NPRS មិនបានទទួលការអើពើពីសភាឡើយ។
- វេទិកាសាធារណៈ ដូចជាវេទិកាដែលរៀបចំឡើងដោយ NGO " មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម " អាចផ្តល់ឱកាសអោយប្រជាជន ចូលរួមជាមួយអ្នកធ្វើសេចក្តីសំរេចចិត្ត។ NGOs ជាច្រើនចង់ឃើញការត្រលប់ទៅរកសមាជជាតិមួយ ដែលក្នុងវេទិកានោះ ប្រជាជនអាចចូលរួម និងសួរសំណួរ ចំពោះថ្នាក់ដឹកនាំរដ្ឋាភិបាលនៅថ្នាក់ជាតិ។ វេទិកានេះធ្លាប់បានធ្វើនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ហើយក៏ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

ចុងក្រោយនេះដែរ ប៉ុន្តែមិនដែលបានធ្វើនៅពេលកន្លងមកឡើយ។

- អាចធ្វើទំនាក់ទំនងបន្ថែមទៀត រវាងដំណើរការធ្វើផែនការថ្នាក់ជាតិ និងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តថ្នាក់វិមជ្ឈការមូលដ្ឋាន ដើម្បីធានាអោយមានលំហូរពតិមានពីថ្នាក់ក្រោមទៅថ្នាក់លើ។ បច្ចុប្បន្ននេះ ដំណើរការនៃការធ្វើផែនការនៅកម្ពុជា គឺដាក់បញ្ចូលផែនការថ្នាក់ឃុំ ទៅក្នុងផែនការថ្នាក់ខេត្ត ក៏ប៉ុន្តែនៅមិនទាន់មានទំនាក់ទំនងជាមួយនឹងដំណើរការ នៃផែនការថ្នាក់ជាតិនៅឡើយ។
- នៅក្នុងប្រទេសមួយចំនួន NGO បង្កើតជា ការស្ទាបស្ទង់ " *ដោយបំពេញរបាយការណ៍លើប័ណ្ណមួយ* " ដែលប្រមូលមតិយោបល់ដែលមានលក្ខណៈជាប្រព័ន្ធ ពីសាធារណៈជន ទៅលើគុណភាព និងប្រសិទ្ធភាពនៃសេវារបស់រដ្ឋាភិបាល។ នៅកម្ពុជា NGO មួយចំនួនកំពុងដាក់ចេញនូវដំណើរការស្រដៀងគ្នានេះ ដើម្បីតាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃកំណែទំរង់វិមជ្ឈការ ។
- នៅកម្ពុជា មានការស្រាវជ្រាវខ្លះៗមកហើយ និងបន្តស្រាវជ្រាវទៀត ដើម្បីប្រមូលពតិមានពីក្រុមគោលដៅ ជាពិសេស គឺការវាយតំលៃភាពក្រីក្រដោយមានការចូលរួម។ ពតិមានដែលទទួលបានពីការវាយតំលៃទាំងនេះ ត្រូវដាក់បញ្ចូលទៅ ក្នុងការធ្វើសេចក្តីសំរេចចិត្តតាមរបៀបមួយកាន់តែមានលក្ខណៈជាប្រព័ន្ធ។
- NGOs អាចជួយសំរួលដល់ការចូលរួម ជាមួយប្រភេទអង្គការសង្គមស៊ីវិលផ្សេងៗទៀត រួមមាន សហជីពកម្មករ សមាគមជនជាតិភាគតិច សមាគមកសិករជាដើម។ NGO ក៏អាចជួយរៀបចំកិច្ចប្រជុំ រវាងមន្ត្រីនិងសហគមន៍ជនបទ តាមរបៀបមួយដែលនាំទៅរកការចែករំលែកបញ្ហាគ្នាពិតប្រាកដ។

ក្នុងគ្រប់ដំណើរការទាំងនេះ កត្តាដែលសំខាន់បំផុត គឺការចូលរួមរបស់ *អ្នកក្រីក្រ* និង *ក្រុមជនងាយរងគ្រោះ* ពោលគឺអ្នកដែលយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ មានបំណងជួយដល់ពួកគេ។

## ២.៤ តួនាទីរបស់ផ្នែកឯកជន

NGOs ទទួលស្គាល់នូវសារៈសំខាន់របស់ផ្នែកឯកជន នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចមួយដ៏ខ្លាំង ដែលនឹងផ្តល់នូវមូលដ្ឋានសេដ្ឋកិច្ចមួយកាន់តែមានស្ថេរភាព ក្នុងការផ្តល់សេវាសង្គម និងបង្កើនឱកាសការងារ។ RGC ត្រូវស្តាប់ពីកង្វល់របស់ផ្នែកឯកជនដោយយកចិត្តទុកដាក់ ជាពិសេស ពាក់ព័ន្ធ នឹងការកាត់បន្ថយតំលៃអាជីវកម្ម និងភាពមិនច្បាស់លាស់ តាមរយៈការកាត់បន្ថយអំពើពុករលួយ និងឧបសគ្គរដ្ឋបាលដែលមិនចាំបាច់។ គ្រប់ប្រតិបត្តិករផ្នែកឯកជនទាំងអស់ ត្រូវទទួលបាននូវការគោរពស្មើៗគ្នា ដើម្បីផ្តល់នូវទីលានប្រកួត ប្រជែងស្មើភាពគ្នាដែលអាចទស្សន៍ទាយបាន ំរាប់សកម្មភាពអាជីវកម្ម។

ទន្ទឹមនឹងនេះ NGOs សង្ឃឹមថា រាល់កិច្ចខិតខំប្រឹងប្រែងដើម្បីប្រែក្លាយកម្ពុជាអោយទៅជាប្រទេសមួយ ដែលទាក់ទាញចំពោះវិនិយោគទុនបរទេស ត្រូវថ្លឹងថ្លែងអោយបានត្រឹមត្រូវ ជាមួយនឹងផលប្រយោជន៍របស់អ្នកក្រ។ សម្បទានពន្ធ កាត់បន្ថយចំណូលរបស់រដ្ឋាភិបាលដែលមានសំរាប់ផ្នែកសង្គម ហើយត្រូវកំណត់អោយបានតឹងតែង។ ប្រតិបត្តិករផ្នែកឯកជនក្នុងស្រុក និងសហគ្រាសធុនតូចគួរតែត្រូវបានចាត់ទុកថា ជាធនធានសារវ័ន្តសំរាប់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ ជំនួយនៅតែត្រូវការដើម្បីប្រតិបត្តិករផ្នែកឯកជនក្នុងស្រុក ដើម្បីជំនះនូវឧបសគ្គផ្នែកសមត្ថភាព និងសង្វាក់ផ្គត់ផ្គង់។

ទន្ទឹមនឹងគាំទ្រដោយផ្នែកឯកជនដ៏ខ្លាំងក្លា ផ្នែកសាធារណៈត្រូវធ្វើជាអ្នកដឹកនាំ ក្នុងការផ្តល់សេវាមូលដ្ឋានផ្សេងៗ

ដូចជាសុខាភិបាល និងអប់រំ និងក្នុងការរៀបចំគ្រប់គ្រង ការផ្តល់សេវាផ្នែកឯកជន ដើម្បីអោយឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជនកម្ពុជាអោយបានត្រឹមត្រូវ ។

# ៣. ការរីកចំរើន បញ្ហា និងអនុសាសន៍

## ៣.១ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអនុវត្តថវិកា

តុល្យភាពរវាងកំណើនម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលបានកំណត់ដោយ RGC នៅក្នុង NPRS មានឫសគល់ចេញពីគំនិតនៃការលើកកំពស់ " កំណើនទូលំទូលាយជានិរន្តរ៍ ប្រកបដោយសមធម៌ "។ កំណើនសេដ្ឋកិច្ចលឿន គឺជាគំនិតសំខាន់នៃយុទ្ធសាស្ត្រ ដែលតាមរយៈនេះ អ្នកក្រកាន់តែទទួលបាន " ឱកាសរកប្រាក់ចំណូលថែមទៀត" ។

ទោះជាយ៉ាងនេះក្ដី ដូចដែលសហគមន៍ NGO បានលើកឡើងច្បាស់ នៅក្នុងសេចក្ដីថ្លែងការណ៍នៅឯកិច្ចប្រជុំ CG ឆ្នាំ ២០០២ កំណើនបែបនេះ តែងតែកើតឡើងដោយបង្កមហន្តរាយដល់បរិស្ថាន ការបែកបាក់សង្គម និង កំណើននៃវិសមភាព ជាពិសេសនៅពេលគ្មានវិធានការដែលមានប្រសិទ្ធភាពផ្នែកបរិស្ថាន និងសង្គម ដើម្បីគ្រប់គ្រងផលវិបាកទាំងនេះ។

### ៣.១.១ ការរីកចំរើន

សូចនាករសេដ្ឋកិច្ចបច្ចុប្បន្ននេះបង្ហាញថា ក្នុងកំឡុងពេលពាក់កណ្ដាលទីមួយនៃឆ្នាំ ២០០៣ កម្ពុជារងគ្រោះពីដំណើរសេដ្ឋកិច្ចដ៏លំបាកមួយ។ ប្រការនេះ ត្រូវបានទំលាក់កំហុសលើកត្តាអស្ថេរភាពនយោបាយដ៏ធំធេង និង ភាពមិនច្បាស់លាស់ ជាពិសេសបបន្ទាប់ពីមានកុបកម្ម ប្រឆាំងនឹងប្រទេសថៃ និងពេលឈានទៅរកការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ លើសពីនេះទៅទៀត ការផ្ទុះឡើងនូវជំងឺ SARS នៅក្នុងតំបន់ បានផ្ដល់នូវផលវិបាកមកលើវិស័យទេសចរណ៍។

សូចនាករអវិជ្ជមានទាំងនេះរួមមាន អត្រាកំណើនសេដ្ឋកិច្ច ៤,៥% នៅឆ្នាំ ២០០៣ ដែលធ្លាក់ចុះពី ៥,៥% នៅឆ្នាំ ២០០២ បើទោះបីជា RGC ប្ដេជ្ញាចិត្តនឹងសំរេចអោយបាន ពី ៦-៧%ក៏ដោយ។ អត្រាកំណើនសេដ្ឋកិច្ចទាបនេះមិនអាចគ្រប់ គ្រាន់ក្នុងការកាត់បន្ថយកំរិតភាពក្រីក្ររបស់ប្រជាជនបានឡើយ ប្រសិនបើគ្មានការបែងចែកធនធានឡើងវិញទេនោះ។

ចំណូលរបស់រដ្ឋាភិបាល ធ្លាក់ចុះពី ១,៧% ក្នុងរយៈពេល ១១ ខែដំបូងនៃឆ្នាំ ២០០៣ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទោះបីជាយ៉ាងនេះក្ដី អត្រាអតិផរណាស្ថិតនៅក្នុងកំរិត ១,២% ធ្លាក់ចុះពី ៣% នៅឆ្នាំ ២០០២។

ការអនុវត្តថវិកា នៅតែមិនមានលក្ខណៈល្អប្រសើរ។ ផ្នែកសង្គមនៅតែជាវិស័យមួយ ដែលមិនមានធនធានគ្រប់គ្រាន់ ដោយក្រសួងអប់រំទទួលបានតែ ៧៩% នៃថវិការបស់ខ្លួន ចំណែកឯក្រសួងសុខាភិបាលទទួលបាន ៥៩% ហើយក្រសួងអភិវឌ្ឍន៍ជនបទទទួលបានតែ ៥៤%។ ផ្ទុយទៅវិញ ទីស្ដីការគណៈរដ្ឋមន្ត្រីចំណាយ ១០៩% នៃថវិការបស់ខ្លួន ក្រសួងមហាផ្ទៃចំណាយ ១៦៧% ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណាយ ១៩៩%។ បើទោះជាមានការប្ដេជាចិត្ត ដើម្បីប្ដូរទិសដៅចំណាយ ពីក្រសួងការពារជាតិ មកផ្នែកសង្គមក៏ដោយ ក៏នៅឆ្នាំ ២០០៣ ក្រសួងការពារជាតិ បានទទួលបានទឹកប្រាក់ ១,២៥លានដុល្លារ ច្រើនជាងក្នុងឆ្នាំ ២០០២[៣]។

[3] តួលេខផ្ដល់ដោយ MoFE ដែលត្រូវដកស្រង់ដោយកាសែត *The Cambodia Daily* ចុះថ្ងៃទី ២៩ មករា ឆ្នាំ ២០០៤ និងថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០៤

## ៣.១.២ បញ្ហា

ដូចដែលធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីបានចង្អុលបង្ហាញ ក្នុងការត្រួតពិនិត្យការចំណាយសាធារណៈរួមរបស់ធនាគារទាំងពីរ ក្រោមចំណងជើងថា " ការសាកល្បងដ៏សំខាន់ ទៅលើប្រព័ន្ធ**គ្រប់គ្រងចំណាយសាធារណៈ** គឺជាសមត្ថភាពនៃប្រព័ន្ធនេះ ក្នុងការផ្តល់នូវលំហូរមូលនិធិដែលអាចទស្សន៍ទាយបាន និងទាន់ពេលវេលា ទៅដល់ភ្នាក់ងារដែលត្រូវធ្វើចំណាយ ..."[4] ។ ច្បាស់ណាស់ថា បញ្ហានេះមិនកើតឡើងនៅកម្ពុជាឡើយ ។ និយាយមែនទែនទៅ ប្រាក់មិនត្រូវបានបើកផ្តល់ស្មើគ្នា ឬអាចទស្សន៍ទាយបានឡើយ នៅក្នុងមួយឆ្នាំៗ ។ បញ្ហានេះ នាំអោយផ្នែកជាច្រើនជួប " រដូវប្រាំង" គ្មានលុយ ដែលនឹងលើកយកមកនិយាយនៅក្នុងផ្នែក ៣.៤ ពាក់ព័ន្ធនឹងសុខាភិបាល ។ RGC ត្រូវធានាថា ការគ្រប់គ្រងការចំណាយរបស់ខ្លួនស្ថិតនៅក្រោមការវាយតំលៃការអនុវត្តថវិកា ដ៏មានប្រសិទ្ធភាព ដើម្បីធានាបែងចែកប្រាក់អោយបានទាន់ពេលវេលា និងគ្រប់ចំនួន ។

ក្នុងករណីដែលមាន **កំណើន** វាបានកើនឡើងតិចតួច ដែលបានផ្តល់ផលប្រយោជន៍ដល់មនុស្ស មួយចំនួនតូចប៉ុណ្ណោះ ។ អ្នកពាក់ព័ន្ធទាំងអស់គាំទ្រនូវការ ផ្តោតការយកចិត្តទុកដាក់ លើកំណើនប្រកបដោយសមធម៌ ប៉ុន្តែវានឹងមិនអាចកើតឡើងបានដោយគ្មានវិធានការ ដើម្បីដាក់ការកាត់បន្ថយភាពក្រីក្រ នៅក្នុងចំណុចកណ្តាលនៃគ្រប់នយោបាយសារពើពន្ធ រូបិយវត្ថុ និងពាណិជ្ជកម្ម និងដោយគ្មានដំណើរការវាយតំលៃពីនយោបាយទាំងនោះឡើយ ។ រហូតមកដល់ពេលនេះ មានសញ្ញាតិចតួចក្នុងការប្រើប្រាស់យុទ្ធវិធីបែបនេះ ក្នុងការអនុវត្ត NPRS ។

ការប្រមូល **ចំណូល** ទាប រារាំងដល់លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការពង្រីកចំណាយសង្គមនៅកម្ពុជា ។ ការប្តេជ្ញាចិត្តដែលបានលើកឡើងនៅក្នុង NPRS បង្ហាញថា នៅប៉ុន្មានឆ្នាំខាងមុខនេះ នឹងមានតំរូវការយ៉ាងច្រើន ដើម្បីអោយរដ្ឋាភិបាលបង្កើនចំណូល ។ WB និង ADB បានថ្លែងថា " បើគ្មានកំណើនចំណូលច្រើនទេ មានហានិភ័យយ៉ាងធ្ងន់ធ្ងរ ទាំងចំពោះនិរន្តរភាពម៉ាក្រូសារពើពន្ធរយៈពេលមធ្យម និងកម្មវិធីកាត់បន្ថយភាពក្រីក្ររយៈពេលមធ្យម របស់ RGC[5] ។

ចំណូលដែលបានមកពីប្រព័ន្ធយកពន្ធ នៅតែមានកំរិតទាប បើទោះបីជាមានការផ្តល់ជំនួយបច្ចេកទេស ក្នុងវិស័យនេះក្តី ។ ត្រូវការនូវគ្រប់គ្រងប្រព័ន្ធយកពន្ធអោយកាន់តែប្រសើរ ។ តម្លាភាពកាន់តែខ្លាំងជាងមុន និងការផ្តល់ពត៌មានសាធារណៈអំពីបញ្ហាសេដ្ឋកិច្ច និងសារពើពន្ធ មានសារៈសំខាន់ប្រសិនបើមានការកែលំអរ នៅក្នុងការតាមដានត្រួតពិនិត្យ ជាពិសេសនៅថ្នាក់មូលដ្ឋាន ។

ការគំរាមកំហែងបន្ថែមទៀត ដល់ការគ្រប់គ្រងថវិកាជាតិនៅពេលអនាគត គឺបរិមាណកើនឡើង ដែលនឹងត្រូវបង់ក្នុង**ការសងបំណុល** ដែលអាចមានចំនួន ៩% ឬលើសពីនេះនៃការចំណាយបច្ចុប្បន្ន ចាប់ពីឆ្នាំ ២០០៩ទៅ[6] ។ ក្នុងខណៈដែលកម្ពុជាមិនសូវមានបំណុលច្រើន សមត្ថភាពទាបរបស់កម្ពុជាក្នុងការប្រមូលចំណូល ធ្វើអោយការសងបំណុលជាបន្ទុកសារពើពន្ធមួយដ៏ធ្ងន់ធ្ងរ ។ បំណុលមួយផ្នែកធំរបស់កម្ពុជា គឺជំពាក់សហរដ្ឋអាមេរិក ចំពោះការគាំទ្ររបស់

---

4 *កម្ពុជា :* ការវាយតំលៃការជឿទុកចិត្តសរុប និងការសើរើចំណាយសាធារណៈ ខែ កញ្ញា ឆ្នាំ ២០០៣ ទំព័រទី ៦៩

5 ក្នុងរបាយការណ៍រួមគ្នា *កម្ពុជា : ការវាយតំលៃការជឿទុកចិត្តសរុប និងការពិនិត្យការវាយតំលៃចំណាយសាធារណៈ បោះពុម្ពនៅខែ កញ្ញា ឆ្នាំ ២០០៣ ទំព័រ* viii

6 MoEF: *សេចក្តីព្រាង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ខែ មករា ២០០៤ តារាងទី ៧.៤*

អាមេរិកនៅសម័យ លន់ នល់ និង ជំពាក់រុស្ស៊ី ចំពោះការគាំទ្ររបស់រុស្ស៊ីក្នុងទសវត្សរ៍ឆ្នាំ ១៩៨០។

RGC ទទួលស្គាល់ថា ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម នៅតែមានលក្ខណៈផុយស្រួយ ដែលនាំអោយកម្ពុជាជួបប្រទះនូវបញ្ហាចំពោះមុខធ្ងន់ធ្ងរជាច្រើន។ ជាពិសេសការពឹងផ្អែកលើវិស័យវាយនភ័ណ្ឌបច្ចុប្បន្ន ធ្វើអោយសេដ្ឋកិច្ចប្រទេសរងការធ្លាក់ចុះនៃសេដ្ឋកិច្ច ដែលជាលទ្ធផលនៃការផ្តាច់ចំនួនកូតា និងការប្រឈមមុខចំពោះលក្ខខណ្ឌនានានៅពេលចូលជាភាគី WTO។

ភាពមិនច្បាស់លាស់នៅក្នុងគ្រប់ផ្នែក នៃសេដ្ឋកិច្ចរួមទាំងផ្នែកកសិកម្ម ឧស្សាហកម្ម និងសេវា ធ្វើអោយមានការលំបាកក្នុងការធានាអោយមាន មូលដ្ឋានហិរញ្ញវត្ថុត្រឹមត្រូវមួយសំរាប់ការកាត់បន្ថយភាពក្រីក្រ និងកំណើន នៅក្នុងរយៈពេលមធ្យម។ ដើម្បីសំរេចបានកំណើនយូរអង្វែង RGC ត្រូវធ្វើអោយមានវឌ្ឍនភាពពិតប្រាកដ ចំពោះការប្តេជ្ញាចិត្តដែលបានលើកឡើងក្នុង NPRS។ ការប្តេជ្ញាចិត្តទាំងនេះរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ការបង្កើនចំណាយសំរាប់ផ្នែកសង្គម លើកកំពស់អភិបាលកិច្ច កែទំរង់មន្ត្រីរាជការ និងកែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ។

**កំណែទំរង់ស្ថាប័ន** ដើម្បីកាត់បន្ថយអំពើពុករលួយ និងនីរទណ្ឌភាព និងលើកកំពស់សមធម៌ និងកិច្ចអភិវឌ្ឍមានសារៈសំខាន់ក្នុងរយៈពេលមធ្យម។ កំណែទំរង់បែបនេះទាមទារអោយគិតគូរពិចារណា នូវបញ្ហាគន្លឹះមួយចំនួនដូចខាងក្រោម :

១. ផលវិបាកនៃ **អំពើពុករលួយ** នៅគ្រប់កំរិតនៃ សេដ្ឋកិច្ចមានផលវិបាកអវិជ្ជមានយ៉ាងច្រើន លើកំណើនសេដ្ឋកិច្ចព្រមទាំងសកម្មភាពឧក្រិដ្ឋផ្សេងៗ ដូចជាការរត់ពន្ធកើតឡើងនៅគ្រប់ទីកន្លែង ការគេចពន្ធ និង អំពើប្លន់។

២. **សមត្ថភាពរបស់ស្ថាប័ន** ត្រូវពង្រឹងអោយបានខ្លាំងក្លាដើម្បីលើកកំពស់ទំនុកចិត្តក្នុងការគ្រប់គ្រងសេដ្ឋកិច្ច។

៣. **តម្លាភាព** ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច មានសារៈសំខាន់ចំពោះអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអោយពួកគេ អាចយល់ដឹង និងតាមដានស្ថានភាពសេដ្ឋកិច្ច និងការបែងចែកមូលនិធិ សំដៅកាត់បន្ថយភាពក្រីក្រ។

### ៣.១.៣. អនុសាសន៍

- ជាថ្មីម្តងទៀត សហគមន៍ NGO ស្នើអោយ មានការវិភាគពីផលប៉ះពាល់លើភាពក្រីក្រ និងសង្គមទាំងស្រុងមួយ ដែលបណ្តាលមកពីគោលនយោបាយសារពើពន្ធរូបិយវត្ថុ និងពាណិជ្ជកម្ម ដើម្បីអោយឧបករណ៍គោលនយោបាយទាំងនេះ ដែលនឹងផ្តោតគោលដៅទៅលើអ្នកក្រនោះ ត្រូវបានបញ្ចូល។
- សហគមន៍ NGO ស្នើអោយ RGC កំណត់ អាទិភាពកំណែទំរង់ទៅលើប្រព័ន្ធគយ និង ពន្ធ និងដាក់អោយអនុវត្តនូវប្រព័ន្ធមួយ ដែលមានប្រសិទ្ធភាព។
- សហគមន៍ NGO ជំរុញអោយ RGC បន្ត ធ្វើកំណែទំរង់ប្រព័ន្ធបើកផ្តល់ថវិកា និងពង្រឹងប្រព័ន្ធគ្រប់គ្រងថវិកា ខាងក្នុង និង ខាងក្រៅ ដូចជាតាមរយៈប្រព័ន្ធសវនកម្ម ដែលមានប្រសិទ្ធភាព កំណើនតម្លាភាព និងការពង្រឹងសមត្ថភាពស្ថាប័ន។ ចាំបាច់ត្រូវផ្តល់ធនធានហិរញ្ញវត្ថុទៅអោយក្រសួងនានា ដោយគ្មានភាពលំអៀងផ្នែកនយោបាយ។
- រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ត្រូវតែធ្វើឡើងដើម្បីរៀបចំនូវតារាងបំណុល ដែលជំពាក់សហរដ្ឋអាមេរិក និងរុស្ស៊ីឡើងវិញ។ សហរដ្ឋអាមេរិក អាចពិចារណាការលើកលែងបំណុលខ្លះ ដែលជាផ្នែកមួយនៃជំនួយរបស់ខ្លួនមកកម្ពុជា។

- សភាជាតិគួរពិភាក្សា ក៏រិតចំនួនប្រាក់កម្ចី ដែលនឹងត្រូវទទួលយកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដោយគិតគូរពិចារណាទាំងលើ សេចក្តីត្រូវការរបស់ប្រទេសផង និងសមត្ថភាពរបស់ប្រទេស ក្នុងការស្រូបទាញជំនួយប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់ពីក៏រិតនៃការសងបំណុល និងថវិកាទៅអនាគត។ កម្ចីដែលគ្មានសម្បទាន គួរតែចៀសវាងជាដាច់ខាត។

## ៣.២. ការលើកកំពស់ជីវភាពជនបទ

NPRS លើកឡើងថាកសិកម្មនិងអភិវឌ្ឍន៍ជនបទ គឺជាអាទិភាពគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ។ ការយកចិត្តទុកដាក់លើជីវភាពជនបទ សង្កត់ធ្ងន់លើបញ្ហា ដូចជា ដីធ្លី ធនធានធម្មជាតិ ទឹក កសិកម្ម និងដឹកជញ្ជូន។

សារៈសំខាន់កសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ មិនអាចនិយាយាពន្លើសបានទេ។ ប្រជាជនកម្ពុជាក្រីក្រ ចំនួន ៧៥% រស់នៅក្នុងគ្រួសារដែលមានជីវភាពពឹងផ្អែកលើវិស័យកសិកម្ម។ ជីវិតរបស់ពួកគេ ពឹងផ្អែកទាំងទៅលើការទទួលបានដីធ្លីធ្វើស្រែចំការ និង ធនធានទ្រព្យសម្បត្តិធម្មតាជាពិសេស ផលិតផលត្រី និងព្រៃឈើ។ ការទទួលបានជានិរន្តរ៍នូវធនធានទាំងនេះ គឺជាសារៈសំខាន់នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។

### ៣.២.១ ការរីកចំរើន

នៅឆ្នាំ ២០០៣ ផ្លូវលំជនបទប្រវែង ១០០០ គម. ត្រូវបានសាងសង់ ជីកអណ្ដូងចំនួន ៧០០ និងដីស្រោចស្រពកសិកម្មបានកើនឡើង ២០.០០០ ហិកតា។ សេចក្ដីព្រាងអនុក្រឹត្យស្ដីពីសហគមន៍ជលផល ត្រូវបានបញ្ចប់និងផ្ញើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី រីឯសេចក្ដីព្រាង អនុក្រឹត្យស្ដីពីសហគមន៍ព្រៃឈើ ត្រូវបានឯកភាពជាចុងក្រោយ។

ការចំណាយរបស់ MoEF នៅតែមិនត្រូវបានបែងចែកអោយបានគ្រប់គ្រាន់ចំពោះអាទិភាពកាត់បន្ថយភាពក្រីក្រឡើយ។ ការចំណាយផ្នែកកសិកម្ម នៅតែមានចំនួនតិចជាង ១% នៃការចំណាយចរន្តផ្នែកកសិកម្ម។ សុខភាពសត្វ និងកៅ្យត្រសាស្ត្រ ក៏ហាក់ដូចជាមានចំណែកនៃការចំណាយតិចតួចដែរ[7]។

### ៣.២.២ បញ្ហា

បើទោះបីជានៅក្នុង NPRS គឺជាវិស័យគន្លឹះសំរាប់កិច្ចអភិវឌ្ឍក៏ដោយ ក៏វិស័យជនបទនៅមានមូលនិធិមិនគ្រប់គ្រាន់។ ចំពោះ RGC ក្នុងការបំពេញគោលបំណងរបស់ខ្លួនក្នុងការបង្កើនចំណូលជនបទ ត្រូវមានការផ្លាស់ប្ដូរជាដុំកំភួនមួយចំនួន នៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាល និងការគាំទ្ររបស់ម្ចាស់ជំនួយ។

ការបញ្ចប់ភាពប្រទូស្ដរ៉ាយគ្នា និងផ្លូវថ្នល់កាន់តែល្អប្រសើរឡើង បានពន្លឿនការនាំចូលផលិតផលកសិកម្មដែលមានលក្ខណៈប្រកួតប្រជែង ជាងផលិតផលក្នុងស្រុក។ ជាមួយនឹងការចូលក្នុង WTO របស់កម្ពុជា កម្ពុជាកាន់តែត្រូវធានាគាំទ្រកសិករ និងកសាងសមត្ថភាពពួកគេ ក្នុងការប្រឈមមុខនឹងពាណិជ្ជកម្មសេរី។ ការកើនឡើងនៃសំពាធលើដីធ្លី និងធនធានធម្មជាតិ បានបន្ថែមទៅដល់បញ្ហាដែលកសិករតូចតាច និងអ្នកក្រីក្របានប្រឈមមុខរួចមកហើយ។ បើទោះបីជា NPRS នៅតែផ្ដោតការយកចិត្តទុកដាក់ លើការអភិវឌ្ឍន៍ទ្រទ្រង់អ្នកក្រ ក៏ដោយ រដ្ឋាភិបាលហាក់ដូចជាផ្ដោតលើការផ្ដល់ **សម្បទានកសិកម្មទ្រង់ទ្រាយធំ** ចំពោះផ្នែកឯកជន គឺៈ

- តួលេខលេខផ្ដល់ដោយ MAFF នៅដើមឆ្នាំ ២០០៣ បង្ហាញថា នៅក្នុងឆ្នាំកន្លងមកថ្មីៗនេះ ទីស្ដីការគណៈរដ្ឋមន្ត្រី បានអនុម័តដីសម្បទានចំនួន ៤០ សំរាប់គោល

---

[7] RGC, របាយការណ៍ស្ដីពីការរីកចំរើន នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ សេចក្ដីព្រាង ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៣

បំណងកសិកម្ម ដែលគ្របដណ្ដប់លើផ្ទៃដីចំនួន ៨០០.០០០ ហិកតា ឬ ៤% ផ្ទៃដីកម្ពុជា។

ផលចំណេញដែលបានមកពីសម្បទានអភិវឌ្ឍន៍ទាំងនេះ មានភាពមិនច្បាស់លាស់ ដោយហេតុថា ការធ្វើចំការធំៗហាក់ដូចជាបង្កើតនូវភាពគ្រោះថ្នាក់ និងជំលោះជុំវិញការទទួលបានដីធ្លី ដែលជាការកាត់បន្ថយការទទួលបានធនធានធម្មជាតិ និងផ្ដល់ការងារតិចតួចដល់ប្រជាជនជនបទ។ ការរកចំណូលហាក់ដូចជាប្រមូលផ្ដុំតែនៅលើគ្រួសារ ដែលមានជីវភាពធូរធាររួចហើយ និងក្រុមហ៊ុនដែលមានលទ្ធភាពវិនិយោគលើកសិឧស្សាហកម្មខ្នាតធំ។ លើសពីនេះទៅទៀត ការប្ដេជ្ញាចិត្តរបស់ NPRS ដើម្បីជំរុញការធ្វើចំការកសិឧស្សាហកម្ម បានផ្ដល់សំពាធថែមទៀតលើព្រៃឈើតាមរយៈការបែងចែកដីព្រៃឡើងវិញ សំរាប់ផលិតកម្មកសិកម្ម។

ផ្ទុយមកវិញ សហគមន៍ NGO សូមស្នើអោយមានការផ្ដោតការយកចិត្តទុកដាក់លើការពង្រីក **ប្រពលវប្បកម្ម** ចំពោះកសករតូចតាច និងផ្គត់ផ្គង់ **ឧបករណ៏ធារាសាស្ត្រខ្នាតតូចដែលថៃទាំដោយអ្នកប្រើប្រាស់** និងការអនុវត្តនូវ **វិធី-សាស្ត្រដែលចំណាយដើមទុនតិច** ក្នុងការបង្កើតកសិផល។

រដ្ឋាភិបាលកម្ពុជា និងសមាជិកមួយចំនួននៃសហគមន៍អ្នកផ្ដល់ជំនួយ កំពុងតែរីករាយប្រកាសជាសាធា-រណៈអំពីការកើនឡើងនូវ**ផលិតផលកៅស៊ូ** ។ ការកោតសរសើរប្រកបដោយការរីករាយនេះ ហាក់ដូចជាមិនបានគិតដល់និន្នាការធ្លាក់ចុះរយៈពេលវែង នៃតំលៃជ័រកៅស៊ូនៅក្នុងទីផ្សារអន្តរជាតិ និងការជំនួសកៅស៊ូធម្មជាតិ ដោយជ័រកៅស៊ូសំយោគ។ ផ្ទុយទៅវិញ មានការគាំទ្រតិចតួចចំពោះការចៀរជ័រកៅស៊ូតាមបែបប្រពៃណី បើទោះបីជាតំលៃអន្តរជាតិសំរាប់ជ័រទឹក (dipterocarp) បានកើនឡើងយ៉ាងច្រើន ចាប់តាំងពីឆ្នាំ ១៩៧០ ដោយសារការកាប់ព្រៃឈើទ្រទ្រង់ទ្រាយធំ នៅប៉ុន្មានទសវត្សរ៍នេះ នៅក្នុងដែនកោះអាស៊ីអគ្នេយ៏ក៏ដោយ ។ លើសពីនេះទៅទៀត ដើម្បីទ្រទ្រង់ដល់ជីវភាពបែបប្រពៃណី ការលើកកំពស់ការចៀរជ័រ នឹងជួយដល់ការថែរក្សាព្រៃឈើយកជ័ររបស់កម្ពុជា។

ចំណែកឯការកត់សំគាល់ជាវិជ្ជមានវិញ នឹងទទួលស្វាគមន៍ជានិច្ចចំពោះសកម្មភាពរបស់សហគមន៍ ដើម្បីបង្ការការកាប់ឈើខុសច្បាប់ ដែលគាំទ្រដោយមន្ត្រីរដ្ឋបាលមូលដ្ឋាន និងបង្ហាញអោយឃើញនូវសក្ដានុពល សំរាប់**ការគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋាន**។ ការរីកចំរើនក៏សង្កេតឃើញផងដែរថា កើតមានក្នុងការបង្កើតសហគមន៍ជលផលដែរ។ ត្រូវបង្កើនល្បឿនការកសាងសមត្ថភាពថ្នាក់មូលដ្ឋាន ដើម្បីធានាថាធនធានត្រី ត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព។

**កំណែទំរង់ដីធ្លី** កំពុងតែបន្ត ហើយការវិវត្តរហូតមកទល់ពេលនេះ ត្រូវបានទទួលស្វាគមន៍ដោយ NGOs។ តែទោះជាយ៉ាងណាក៏ដោយ កម្មវិធីច្បាប់នៅមានការខ្វះខាតជាច្រើន ដោយត្រូវការអនុក្រឹត្យជាច្រើនទៀតស្ដីពីសម្បទានដី។ មានបញ្ហាធ្ងន់ធ្ងរកើតឡើងជាច្រើនជុំវិញដីដែលមានជីរជាតិល្អ និងដីដែលនៅចំទីតាំងល្អ ដែលកំពុងត្រូវបាន "ទិញ" សំរាប់ទុកលក់យកចំណេញ ដោយអ្នកមាននៅទីក្រុង។ សហគមន៍ NGO មានក្ដីបារម្ភយ៉ាងខ្លាំងអំពីការខកខានរបស់សហគមន៍អភិវឌ្ឍន៍ មិនទទួលស្គាល់ពីគ្រោះថ្នាក់នៅក្នុងការទិញដីកសិកម្ម របស់ពួកអ្នកមានទីក្រុង ដែលធ្វើអោយប្រជាជននៅជនបទ ខ្វះដីសំរាប់ប្រកបរបរកសិកម្ម និងកែប្រែជាអចិន្ត្រៃយ៏នូវប្រជាសាស្ត្រ នៃកម្មសិទ្ធដី។ ភ្នាក់ងារទាំងឡាយដែលគាំទ្រដល់ដំណើរការ ចេញប័ណ្ណកម្មសិទ្ធដី គួរតែតាមដានត្រួតពិនិត្យដោយប្រុងប្រយ័ត្ននូវការវិវត្តន៍នេះ ហើយស្នើឡើងនូវដំណោះស្រាយគោលនយោបាយសមស្រប។

រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការគ្រប់គ្រង **ប្រព័ន្ធចេញប័ណ្ណកម្មសិទ្ធិនេះ**។ ពាក់ព័ន្ធនឹងជំលោះដីធ្លី ការបង្កើតនូវគណៈកម្មការសុរិយោដីត្រូវបានកត់សំគាល់ និងស្វាគមន៍ដោយមានការប្រុងប្រយ័ត្ន ដោយហេតុថានេះ ជាប្រព័ន្ធជំនួសប្រព័ន្ធមួយពីលើកមុន ដែលមិនទទួលបានការពេញចិត្តទាល់សោះ។ តែទោះជាយ៉ាងនេះក្តី ក្រុមការងារផ្នែកដីធ្លី នៅតែរង់ចាំមើលក្រែងលោ គណៈកម្មការថ្មីនេះមានប្រសិទ្ធភាព ក្នុងការដាក់ចេញនូវប្រព័ន្ធដោះស្រាយដោះស្រាយជំលោះមួយ ដែលមានយុត្តិធម៌។ បើទោះបីជាសមាជិករបស់ខ្លួនបានទទួលការបណ្តុះបណ្តាលពេញលេញក៏ដោយ មូលនិធិដែលចាំបាច់នានាមិនទាន់បានផ្តល់ជូនគណៈកម្មការ ដើម្បីអោយគណៈកម្មការនេះអាចបំពេញនូវចំណាយផ្នែកស៊ើបអង្កេត ធ្វើដំណើរ និងរដ្ឋបាលនៅឡើយ។

ការប្រកាសអោយប្រើអនុក្រឹត្យ ស្តីពី**សម្បទានសង្គម** ត្រូវបានទទួលស្វាគមន៍ដោយ NGOs ថាជាការផ្តល់នូវមធ្យោបាយមួយសំរាប់បែងចែកដីទៅដល់អ្នកក្រ ដែលគ្មានដី។ ការអនុវត្តអនុក្រឹត្យនេះ នឹងទាមទារអោយមាននូវការតាមដានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ និងអាចអនុវត្តអនុវត្តបានសមស្របបំផុត ទៅតាមកំរិតមូលដ្ឋានតាមរយៈដំណើរការនៃការធ្វើផែនការប្រើប្រាស់ដី ដោយមានការចូលរួមដែលមានស្រាប់។

ពាក់ព័ន្ធនឹង**ការគ្រប់គ្រងបរិស្ថាន** NGO ស្វាគមន៍នូវគោលដៅ CMDGs សំរាប់និរន្តរភាពបរិស្ថាន។ គោលដៅទាំងនេះបំពេញនូវចន្លោះប្រហោង រវាង NPRS ដែលខកខានមិន បានដោះស្រាយអោយមានប្រសិទ្ធភាព លើបញ្ហាបរិស្ថាន។

ការអភិវឌ្ឍន៍**ហេដ្ឋារចនាសម្ព័ន្ធ** ក៏មានសារៈសំខាន់ ចំពោះការចូលទៅដល់ទីផ្សារ សំរាប់ផលិតផលកសិកម្មផងដែរ។ ជាពិសេស ផ្លូវលំជនបទ និងប្រព័ន្ធធារាសាស្ត្រ នឹងមានបច្ច័យវិជ្ជមានទៅលើចំណូល និងលើគុណភាពនៃការរស់នៅ។ រដ្ឋាភិបាលបានធ្វើអោយមានការវិវត្តន៍ខ្លះៗហើយ នៅក្នុងការធ្វើអោយប្រសើរឡើង និងពង្រីកបណ្តាញផ្លូវលំ ជនបទ ហើយសហគមន៍ NGO ស្វាគមន៍សមិទ្ធផលនេះ។ ទន្ទឹមនឹងនេះ គួរគិតគួរពិចារណាចំពោះឥទ្ធិពលសង្គម នៃការសាងសងផ្លូវលំជនបទ ជាពិសេសនៅក្នុងតំបន់ព្រៃ និង ខ្ពង់រាប ដែលនៅទីនោះផ្លូវថ្នល់អាចបង្កើនល្បឿន នៃការចូលកាន់កាប់ដី និងបំផ្លាញធនធានធម្មជាតិ។

NPRS ហាក់ដូចជាកំណត់ **ការអភិវឌ្ឍន៍ថាមពល** ជាអាទិភាពផ្នែកហិរញ្ញវត្ថុខ្ពស់បំផុត នៅក្នុងម៉ាទ្រីសនៃផែនការសកម្មភាព។ ទោះជាយ៉ាងនេះក្តី និយាយពីសារៈសំខាន់ចំពោះអ្នកក្រវិញ ការផ្តល់អគ្គិសនីគឺមិនសូវមានសារៈសំខាន់ខ្លាំង ជាងការទទួលបាននូវវិស័យជាមូលដ្ឋានមួយចំនួន ដូចជា សុខាភិបាល អប់រំ និងសេវាប្រពលវប្បកម្មឡើយ។

## ៣.២.៣ អនុសាសន៍

សហគមន៍ NGO ផ្តល់នូវអនុសាសន៍ដូចខាងក្រោម:

- ការអភិវឌ្ឍន៍កសិកម្មសំដៅជួយដល់អ្នកក្រ នឹងទទួលជោគជ័យបានតាមរយៈការពង្រីកសេវា ប្រពលវប្បកម្មចំពោះកសិករតូចតាច ដោយផ្តល់ការគាំទ្រចំពោះឧបករណ៍ធារាសាស្ត្រខ្នាតតូច ដែលថែទាំដោយអ្នកប្រើប្រាស់ និងជំរុញការប្រើប្រាស់វិធីសាស្ត្រ ដែលចំណាយថវិកាតិច សំរាប់បង្កើនកសិផល។ គំរោងទាំងឡាយ ត្រូវតែមានឫសគល់ ចេញពីយុទ្ធសាស្ត្រជួយដល់អ្នកក្រីក្រពិតប្រាកដ ដែលនឹងបង្កើនចំណូល និងសន្តិសុខនៅជនបទ។

- ត្រូវបង្ហាញឆន្ទៈនយោបាយ ក្នុងការដោះស្រាយជាមួយបញ្ហាធ្ងន់ធ្ងរនៃការចូលកាន់កាប់ដី ដែលដកហូតដីធ្លីពីគ្រួសារកសិករ ។
- ប្រព័ន្ធសម្បទានសង្គម គួរផ្សព្វផ្សាយដោយ ប្រុងប្រយ័ត្ន តាមរយៈប្រព័ន្ធនៃការធ្វើផែនការប្រើប្រាស់ដី ដោយមានការចូលរួម ដើម្បីអោយ មានការបែងចែកដីទំនេរនៅជនបទ សំរាប់គ្រួសារអ្នកក្រ ។
- ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ គួរផ្ដោតការយកចិត្តទុដាក់ជាសំខាន់ ទៅលើការចូលរួមរបស់សហគមន៍ ដោយមានផ្ដល់ការទ្រទ្រង់ក្នុងការបណ្ដុះបណ្ដាល និងយន្ដការអនុវតដោយផ្អែកតាមវិមជ្ឈការអំណាច ។
- ការផ្ដោតការយកចិត្តទុកដាក់ជាថ្មី លើការអន្ដរាគមន៍ផ្នែកព្រៃឈើ ចំពោះការគ្រប់គ្រង និងការការពាររបស់សហគមន៍ នឹងជួយការពារប្រព័ន្ធជីវៈចំរុះដ៏សំបូរបែបរបស់កម្ពុជា និងជីវភាពរស់នៅរបស់សហគមន៍ជនបទជាច្រើន ។ ឧស្សាហកម្មចៀរជ័រឈើ តំរូវអោយ មានការទទួលស្គាល់ និងការគាំទ្រជាផ្លូវការ ក្នុងខណៈដែលសក្ដានុពលនៃឧស្សាហកម្មចៀរជ័រកៅស៊ូ ទាមទារអោយមានការពិនិត្យពិច័យអោយបានម៉ត់ចត់ ។

## ៣.៣. ការពង្រីកកាលានុវត្តភាពការងារ

NPRS ចែងថា " ការបង្កើតការងារ និង ការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌការងារ គឺជាគន្លឹះសំរាប់កាត់បន្ថយភាពក្រីក្រ" និងសំដៅសំរេចអោយបានតាមគោលដៅទាំងនេះ តាមរយៈការសំរួលដល់ការអភិវឌ្ឍន៍ផ្នែកឯកជន ដោយពង្រីកការនាំចេញ និងទេសចរណ៍។ ចំណុចជាសារវ័ន្តចំពោះយុទ្ធវិធីនេះ គឺការចូលរបស់កម្ពុជាទៅក្នុងអង្គការ WTO និងការបើកចំហប្រទេស ចំពោះការប្រកួតប្រជែងអន្តរជាតិ។

### ៣.៣.១. ការរីកចំរើន

នៅឆ្នាំ ២០០៣ ការងារថ្មីប្រមាណ ៤០០០ ត្រូវបានបង្កើតក្នុងផ្នែកកម្មន្តសាល និង SME ក្នុងខណៈដែលកម្មករថ្មីប្រមាណ ២០០.០០០នាក់ ចូលទៅក្នុងទីផ្សារការងារ។ ជាពិសេសគឺ លក្ខខណ្ឌធាតុអាកាសអំណោយផលបាន រួមចំណែកដល់ការងើបឡើងវិញផ្នែកកសិកម្ម។

កិច្ចប្រជុំ WTO នៅខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុង Cancun បានអនុម័តការចូលជាសមាជិករបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក បើទោះបីជា NGOs សំដែងពីកង្វល់ថា កសិករ និងអាជីវកម្មធុនតូចរបស់កម្ពុជាមិនបានត្រៀមលក្ខណៈអោយបានគ្រប់គ្រាន់ សំរាប់ទទួលយកនូវផលវិបាកនៃពាណិជ្ជកម្មកាន់តែមានលក្ខណៈសេរីនេះ។

នៅខែ តុលា ឆ្នាំ ២០០៣ ILO បានចេញរបាយ-ការណ៍មួយស្ដីពីលក្ខខណ្ឌការងារ នៅក្នុងវិស័យកាត់ដេរ ដែលមានការរីកចំរើននៅក្នុងវិស័យជាច្រើន បើទោះជានៅមានបញ្ហា ជុំវិញការគោរពចំពោះការបើប្រាក់ខែអោយបានត្រឹមត្រូវ ដែលមានការធ្វើការលើសម៉ោងដ៏ច្រើនសន្ធឹកសន្ធាប់ និងការរើសអើងប្រឆាំងនឹងសហជីពកម្មករ។[៨]

### ៣.៣.២. បញ្ហា

NGOs ជឿថា លក្ខខណ្ឌចាំបាច់សំរាប់ជំរុញកំណើនសេដ្ឋកិច្ច គឺការលើកកំពស់អភិបាលកិច្ច ប្រព័ន្ធតុលាការ បង្កើនសមត្ថភាព និងការធ្វើអោយប្រសើរឡើងនូវហេដ្ឋា-រចនាសម្ព័ន្ធ។ ការទទួលបាននូវសិទ្ធិជាមូលដ្ឋានទាំងនេះ នឹងទទួលបានកំណើនកាន់តែមានប្រសិទ្ធភាពលើយុទ្ធសាស្ត្រណាមួយដែលធ្វើអោយធ្លាក់ចុះនូវសិទ្ធិរបស់កម្មករ កាត់បន្ថយការការពារបរិស្ថាន ឬកាត់បន្ថយការទទួលបានដី និងធនធានធម្មជាតិ របស់អ្នកភូមិ។

ផ្នែកឯកជនដឹកនាំការរីកចំរើន មានសារៈសំខាន់ចំពោះយុទ្ធសាស្ត្របង្កើតការងាររបស់ RGC។ តែទោះជាយ៉ាងនេះក្ដី FDI បានធ្លាក់ចុះចាប់តាំងពីឆ្នាំ ១៩៩៩។ ប្រទេសជិតខាងត្រូវបានមើលឃើញថាមានស្ថេរភាពនយោបាយ រងគ្រោះតិចតួចពីអំពើពុករលួយ មាននីតិរដ្ឋប្រសើរជាង និងមានរដ្ឋាភិបាលមួយដែលខ្លាំង និងមានសមត្ថភាពជាង។ កំលាំងពលកម្មនៅកម្ពុជា ត្រូវបានមើលឃើញថា ខ្វះជំនាញ ហើយកម្ពុជានៅរងគ្រោះពីកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ។ កត្តាទាំងអស់នេះទាមទារអោយមានដំណោះស្រាយ ប្រសិនបើត្រូវបង្កើនកាលានុវត្តភាពការងារ។

RGC បានអបអរសាទរចំពោះការអនុម័តអោយកម្ពុជា **ចូលជាភាគីនៃអង្គការ WTO** ថាជាការបោះជំហានមួយយ៉ាងសំខាន់ ក្នុងការស្វែងរកយុទ្ធសាស្ត្រពាណិជ្ជកម្មទ្រទ្រង់អ្នកក្រ។ តែទោះជាយ៉ាងនេះក្ដី សហគមន៍ NGO នៅតែមានក្ដីបារម្ភអំពី ផលវិបាកអវិជ្ជមានដែលអាចកើតមានឡើង ពីការចូលជាសមាជិករបស់ WTO។

---
[8] RGC សេចក្ដីព្រាង របាយការណ៍ស្ដីពីការរីកចំរើននៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៣

បើទោះបីជា NPRS សន្យាធ្វើការវិភាគពីផលប៉ះពាល់មកលើភាពក្រីក្រ និងផ្នែកសង្គមជាមុន" ដើម្បីគិតគូរពិចារណាពីផលវិបាក លើគោលនយោបាយពាណិជ្ជកម្មមកលើអ្នកក្រ គ្មានចំណុចណាមួយត្រូវបានអនុវត្តឡើយ។ ទន្ទឹមនឹងនេះ គ្មានការពិភាក្សាជាសាធារណៈអោយបានគ្រប់គ្រាន់ ជុំវិញការចូលជាភាគី ឬក៏លក្ខខណ្ឌអ្វីខ្លះសំរាប់ការទទួលចូលជាភាគីរបស់កម្ពុជាឡើយ។ បញ្ហាដែលត្រូវគិតពិចារណារួមមាន ផលវិបាកនៃការចូលជាភាគីមកលើកសិករតូចតាច និង សហគ្រាសធុនតូច និងមធ្យម ដែលមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការ ចំពោះកំណើននៃការប្រកួតប្រជែងអន្តរជាតិ នៅក្នុងទីផ្សារក្នុងស្រុក។

ការចូលភាគី WTO ត្រូវបានចាត់ទុកថា មានសារៈសំខាន់ ចំពោះការបន្តជីវិតផ្នែកកាត់ដេរ ដែលនៅបច្ចុប្បន្ន នេះក្តោបលើការនាំចេញរបស់កម្ពុជា ស្ទើរតែទាំងស្រុង និងផ្តល់ការងារប្រមាណ ១៧០.០០០ កន្លែង ដែលប្រើប្រាស បុគ្គលិកភាគច្រើនជាស្រ្តីមកពីតាមខេត្តនានា ។ ការចូលជា ភាគី WTO នឹងផ្តល់នូវលក្ខខណ្ឌនៃប្រទេសដែលទទួល បានការអនុគ្រោះបំផុត (MFN) ដែលសំរាលដល់ផលវិបាក នៃការបញ្ចប់ប្រព័ន្ធកូតាកិច្ចព្រមព្រៀងសំលៀកបំពាក់នៅឆ្នាំ ២០០៥។ ទោះជាយ៉ាងនេះក្តី ការបន្តចូលទៅដល់ ទីផ្សារឧស្សាហកម្មសំលៀកបំពាក់ហាក់ដូចជាស្ថិតនៅឆ្ងាយពីការពិត។ NGO ជំទាស់នូវរាល់កិច្ចខិតខំប្រឹងប្រែងណាមួយ ដែលបង្ខចដល់ស្តង់ដារពលកម្មដើម្បីបង្កើននូវការប្រកួតប្រជែងអន្តរជាតិ។ ការប្រកួតប្រជែងអាចសំរេចបានជោគជ័យបាន តាមរយៈការបង្កើនជំនាញ និងកាត់បន្ថយ ការិយាធិបតេយ្យ និងអំពើពុករលួយ។ ការបង់ប្រាក់ក្រៅផ្លូវការ ទៅអោយមន្ត្រី បង្កើននូវការចំណាយដ៏ធំចំពោះ

កញ្ញា ស្រី ទូច មានអាយុ ២៣ ឆ្នាំ មានស្រុកកំណើតនៅខេត្តព្រៃវែង។ នាងបានមករស់នៅភ្នំពេញ ហើយកំពុងធ្វើការនៅក្នុងរោងចក្រកាត់ដេរមួយ អស់រយៈពេល ៣ ឆ្នាំហើយ។ នាងមិនចូលចិត្តការងារនេះ ឬមិនចូលចិត្តជីវភាពរស់នៅរបស់នាងទេ ហើយនាងតែងតែមានជំងឺជារឿយៗ និងនឹកដល់ស្រុកកំណើត។ ប៉ុន្តែនាងនៅតែបន្តធ្វើការ និងរកប្រាក់ផ្ញើទៅគ្រួសារនាងនៅឯស្រុក។

នាងចាប់ផ្តើមធ្វើការនៅក្នុងរោងចក្រ ព្រោះឪពុកម្តាយនាងមានការលំបាកក្នុងរកប្រាក់ចិញ្ចឹមគ្រួសារ។ នាងនៅចាំឪពុកនាងប្រាប់ថា " កាលពីមុន នៅពេលដែលឯងនៅតូច ពុក ម៉ែ អាចធ្វើស្រូវបានគ្រប់គ្រាន់ទុកហូប ហើយលក់ស្រូវ ដែលនៅសល់ខ្លះទៅថៅកែស្រូវ ប៉ុន្តែនៅពេលនេះ ការធ្វើស្រែត្រូវចំណាយប្រាក់ច្រើនខ្លាំងពេក "។ កញ្ញា ស្រី ទូច ប្រាប់ថា នាងគ្រាន់តែអាចចាំបានថា គ្មានស្រូវគ្រប់គ្រាន់ប៉ុណ្ណោះ ហើយពេលខ្លះដោយសារតែគ្រួសាររបស់នាង ត្រូវយកស្រូវមួយភាគទៅអោយថៅកែលក់ជីដាក់ស្រែ ដើម្បីសងចំពោះជីដែលបានខ្ចី។ នាងបន្ថែមថា នៅពេលខ្លះ គ្រួសារនាងត្រូវលក់ស្រូវយ៉ាងច្រើន ទើបគ្មានស្រូវហូបគ្រប់គ្រាន់ ព្រោះថា "បងប្រុសខ្ញុំឈឺ ហើយត្រូវយកគាត់ទៅមន្ទីរពេទ្យ "។ នៅពេលមួយទៀតនោះ គឺបណ្តាលមកពីគ្រួសារនាងមិនបានទទួលផលទាល់តែសោះ ដោយសារភាពរាំងស្ងួតអូសបន្លាយវែងពេក។ នាងនៅចាំថា " បើទោះជាគ្រួសារនាងបានខ្ចីប្រាក់គេ ដើម្បីចំណាយលើការបូមទឹក ក៏មិនដែលបានគ្រប់គ្រាន់ដែរ ហើយភាពរាំងស្ងួត បានធ្វើអោយស្រូវងាប់អស់នៅក្នុងរដូវនោះ ហើយយើងក៏ខ្វះស្រូវ និងរស់នៅដោយក្តីអស់សង្ឃឹមគ្រប់ពេលវេលា។

" ដូច្នេះហើយ នៅពេលដែលខ្ញុំឮថា មាននារីម្នាក់មកភ្នំពេញដើម្បីធ្វើការនៅក្នុងរោងចក្រនោះ ខ្ញុំនិងម្តាយខ្ញុំបានទៅសាកសួរពត៌មាន តើត្រូវធ្វើដូចម្តេច ដើម្បីអោយលុយគេខ្លះ ជាថ្នូរនឹងការបានការងារធ្វើនៅក្នុងរោងចក្រ។ ចំពោះបញ្ហានេះ គ្រួសារខ្ញុំបានខ្ចីប្រាក់គេយ៉ាងច្រើន ...ប្រហែលជា ១០០ដុល្លារអាមេរិក។គឺក្រោយពេលនេះហើយ ទើបខ្ញុំបានត្រៀម និងយល់ថា ខ្ញុំត្រូវធ្វើការដើម្បីជួយពួកគាត់ អោយរួចផុត

ពីក្តីអស់ សង្ឃឹមនេះ ”។

“ នៅពេលនេះ គ្រួសារខ្ញុំអាចរស់បានតែដោយសារប្រាក់ ដែលខ្ញុំផ្ញើជូនគាត់តែប៉ុណ្ណោះ។ ខ្ញុំមានការលំបាកយ៉ាងខ្លាំង ដែលខ្ញុំត្រូវហូបត្រីតែម្តងគត់ក្នុងមួយសប្តាហ៍។ ខ្ញុំឈឺព្រោះខ្ញុំហូបអាហារមិនល្អ និងធ្វើការធ្ងន់ ព្រោះថា ប្រសិនបើ យើងមិនបានដេរខោអាវអោយបានមួយសំរាប់ទេនោះ យើងមិនបានប្រាក់ទេ ព្រោះថាគេគិតលើចំនួនសំរាប់ខោអាវដែលយើងបានដេរ ”។

កញ្ញា ស្រី ទូច ប្រាប់ថា នៅពេលណាដែលគ្រួសារនាងមានស្រូវខ្លះលក់ ស្រូវនោះមានតំលៃទាបយ៉ាខ្លាំង ព្រោះស្រូវមកពីប្រទេសវៀតណាម ឬប្រទេសថៃ បានធ្វើអោយតំលៃស្រូវកម្ពុជាចុះថោក។ ប៉ុន្តែ ជីរមកពីប្រទេសហ្វីលីពីន ឬអាមេរិកមានតំលៃខ្ពស់យ៉ាងខ្លាំង ហើយប្រភេទពូជស្រូវថ្មីៗ ពឹងផ្អែកលើការប្រើជីរយ៉ាងខ្លាំង។

នាងក៏បាននិយាយថា នាងនៅតែប្រឹងប្រែងរកប្រាក់ ព្រោះនាង ដឹងថាចំពោះស្រី ទូច ធ្វើការក្នុងរោងចក្រ មិនមែនជាការងាយស្រួលឡើយ ហើយនាងមិនអាចធ្វើការក្នុងរោងចក្ររហូតទេ។ “ នៅពេលណា ដែលខ្ញុំឈឺខ្លាំង ខ្ញុំមិនហ៊ានទៅជួបគ្រូពេទ្យទេ ព្រោះខ្ញុំគ្មានប្រាក់នៅសល់ដើម្បីចំណាយទេ។ ខ្ញុំមិនដែលទៅចូលរួមពិធីអាពាហ៍ពិពាហ៍ ឬលំហែរកាយទេ ព្រោះថានេះជាការចំណាយលុយឥតប្រយោជន៏ នៅពេលដែលឪពុកម្តាយរបស់ខ្ញុំ ត្រូវការប្រាក់ពីខ្ញុំ។ ខ្ញុំមានការភ័យខ្លាចបាត់បង់ការងារយ៉ាងខ្លាំង។ មនុស្សជាច្រើននិយាយថា រោងចក្រទាំងអស់នឹងបិទទ្វារក្នុងពេលឆាប់ៗនេះ ហើយប្រសិនបើបិទមែននោះខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ ព្រោះឪពុកម្តាយខ្ញុំនឹងស្លាប់ បើខ្ញុំមិនអាចជួយផ្គត់ផ្គង់ពួកគាត់ទេនោះ។ ស្រីៗជាច្រើនក៏ភ័យខ្លាចបាត់បង់ការងារដែរ។ ការភ័យខ្លាច នេះបណ្តាលមកពីក្តីបារម្ភដូចគ្នា គឺគ្រួសាររបស់គេនឹងរស់នៅ ដោយក្តីអស់សង្ឃឹម បើគ្មានប្រាក់ផ្ញើទៅអោយទេនោះ ”

ក្រុមហ៊ុន ដែលប្រកបអាជីវកម្ម នៅកម្ពុជា និងបន្ថែមនូវភាពមិនច្បាស់លាស់ចំពោះអាជីវកម្ម។

ការគិតគូរបច្ចុប្បន្នរបស់ RGC GMAC និងសហជីព បានបង្ហាញថា កម្ពុជាអាចនឹង ជំរុញអោយមានវិស័យសំលៀកបំពាក់មួយ ដែលមានមោទនភាពចំពោះខ្លួនឯង ដែលមានលក្ខខណ្ឌការងារដែលអាចទទួលបាន និងការការពារចំពោះកម្មករ។ ដើម្បីសំរេចអោយបាននូវកិត្យានុភាពនេះ ត្រូវមានការធ្វើអោយកាន់តែប្រសើរថែមទៀត ក្នុងការអនុវត្តស្តង់ដារនានា។ ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យនេះ ទាំងស្ថាប័នជាតិ និងអន្តរជាតិ ត្រូវបន្តទៅទៀត។ គោលនយោបាយដែលប៉ះពាល់ដល់កម្មករកាត់ដេរ ត្រូវមានការពិភាក្សាជាមួយកម្មករកាត់ដេរផ្ទាល់ និងត្រូវមានការគិតគូរសមស្របចំពោះស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ។ សមាសធាតុគន្លឹះនៅក្នុងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ក្នុងការបង្កើនការប្រកួតប្រជែងអន្តរជាតិ ដែលមានចែងនៅក្នុង NPRS គឺការបង្កើតឡើងនូវតំបន់ឧស្សាហកម្ម និងកែច្នៃសំរាប់ការនាំចេញ។ លើឆាកអន្តរជាតិ EPZs បានបង្ហាញនូវនិន្នាការមួយឆ្ពោះទៅបង្កើត វិនិយោគ ផលិតកម្ម និងតំបន់ដែលទាក់ទាញផលចំណេញ ដោយមានចំណងទាក់ទងធាក់ថយបន្តិចបន្តួច ឬក៏ការវិនិយោគឡើងវិញ ទៅក្នុងសេដ្ឋកិច្ចនៃប្រទេសទទួល។ NGO ព្រួយបារម្ភអំពីលទ្ធភាពនៃថយចុះនៃការងារ និងស្តង់ដាររបរិស្ថាននៅក្នុងតំបន់ទាំងនេះដែលនេះគឺជាការ បាត់បង់ចំណូលពន្ធ និងការបង្កើនវិសមភាពសេដ្ឋកិច្ចបច្ចុប្បន្ន។

**ទេសចរណ៏**ផ្តល់នូវការសន្យាមួយ បើទោះបីជាមានលក្ខណៈប្រែប្រួល ព្រោះជាប្រភពរូបិយប័ណ្ណបរទេស។ តែទោះជាយ៉ាងនេះក្តី សហគមន៏ NGO ព្រួយបារម្ភ ថាតើទេសចរណ៏អាចមានផលវិបាកទ្រទ្រង់ដល់អ្នកក្រផ្ទាល់ដែរឬទេ។ ផលចំណូលដែលបានមកពីទេសចរណ៏ មាននិន្នាការមួយបង្ហូរចេញក្រៅនូវសហគមន៏ ដែលរងការប៉ះពាល់ដោយសារទេសចរណ៏ បើទោះបីជាមានការលើកកំពស់យុទ្ធវិធីទេសចរណ៏វប្បធម៌ និងទេសចរណ៏ ដោយការពារបរិស្ថាន

(eco-tourism) ក៏ដោយ។ បើទោះបីជាខេត្ត សៀមរាប គឺជាមជ្ឈមណ្ឌលទេសចរណ៍មួយក៏ដោយ ក៏ខេត្តនេះនៅតែជាខេត្តមួយដែលក្រីក្រជាងគេដែរ។

> សុខាត្រូវបានលក់អោយជនបរទេសម្នាក់ កាលពីនាងអាយុបាន ១៣ឆ្នាំ ដើម្បីជួយគ្រួសារនាង ក្នុងការបង់ថ្លៃថ្នាំព្យាបាល។ ចាប់ពីពេលនោះមក នាងបានធ្វើជាស្រីពេស្យាក្នុងវិស័យទេសចរណ៍អស់រយៈពេល ២ ឆ្នាំ រហូតដល់នាងធ្លាក់ខ្លួនឈឺ ហើយភ្ញៀវក៏លែងត្រូវការនាងដែរ។ នាងត្រូវបានគេបោះបង់ចោលអោយរស់នៅតាមចិញ្ចើមថ្នល់។ អង្គការ World Vision បានធ្វើការ ជាមួយនាងអស់រយៈពេលជាងមួយឆ្នាំ ខណៈពេលដែលនាងស៊ូទ្រាំនឹងជំងឺអេដស៍។ នាងបានស្លាប់នៅអាយុ ១៦ ឆ្នាំ ក្នុងទំងន់មិនដល់ ២០ គីឡូក្រាមផង។

ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់ទេសចរណ៍ ផលចំណូលមួយចំនួនដែលបានមកពីទេសចរណ៍ត្រូវយកទៅធ្វើការវិនិយោគឡើងវិញការ ការពារកុមារការបណ្ដុះបណ្ដាលនិងស្តង់ដារ។ ដើម្បីសំរេចអោយបាននូវយុទ្ធវិធីចំពោះទេសចរណ៍ប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវធានានូវការចូលរួមរបស់សហគមន៍មូលដ្ឋាន អោយមានកំរិតខ្ពស់។ កិច្ចព្រមព្រៀងរវាងកម្ពុជា វៀតណាម ឡាវ ដើម្បី បង្កើនទេសចរណ៍ នៅក្នុងខេត្តភាគឦសាននៃប្រទេសកម្ពុជា ត្រូវបានប្រាប់អោយដឹងជាមុនថាជាមធ្យោបាយនៃការលើកកំពស់សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ទាំងនេះ។ តែទោះជាយ៉ាងនេះក្តីផលប៉ះពាល់ មកលើជនជាតិដើមនៅក្នុងតំបន់ទាំងនេះ នឹងមានសារៈសំខាន់យ៉ាងធំធេង។ សហគមន៍ NGO ព្រួយបារម្ភថា បើគ្មានការទទួលបានសេវាអប់រំ និងបណ្ដុះបណ្ដាលទេនោះ សហគមន៍ទាំងនេះ នឹងឃ្លាតកាន់តែឆ្ងាយពីសង្គម ជាជាងការជួយទ្រទ្រង់ដោយការអភិវឌ្ឍន៍ទាំងនេះ។

## ៣.៣.៣. អនុសាសន៍

សហគមន៍ NGO ជឿថាកំណើនសំរាប់ទ្រទ្រង់ដល់អ្នកក្រ នឹងសំរេចបានតាមរយៈការគិតគូរ នូវកត្តាទាំងឡាយដូចខាងក្រោម :

- កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ នឹងត្រូវជំរុញ តាមរយៈការលើកកំពស់អភិបាលកិច្ច ប្រព័ន្ធតុលាការ បង្កើនសមត្ថភាព និង ហេដ្ឋារចនាសម្ព័ន្ធ។ ការបង្កើនការវិនិយោគក្នុងការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីបង្កើនជំនាញក្នុងកំលាំងពលកម្ម គឺមានសារៈសំខាន់។
- ត្រូវបន្តសកម្មភាពលុបបំបាត់អំពើពុករលួយ ដែលជាឧបសគ្គមួយយ៉ាងធំចំពោះផ្នែកឯកជន
- តំរូវអោយមានការពិភាក្សាជាសាធារណៈទៅលើជំរើសផ្សេងៗសំរាប់គោលនយោបាយពាណិជ្ជកម្ម។ តំរូវអោយមានការវាយតំលៃផលប៉ះពាល់លើភាពក្រីក្រជាមុន នៃការចូលជាសមាជិក WTO ដើម្បីកំណត់ និងដោះស្រាយចំពោះផលប៉ះពាល់មកលើក្រុមដែលងាយរងគ្រោះដូចជាកសិករតូចតាច។
- ស្តង់ដារការងារ និងសិទ្ធិរបស់កម្មករក្នុងការចូលក្នុងសហជីពណាមួយ មិនគួរត្រូវបានបំផ្លាញ តាមរយៈការខិតខំប្រឹងប្រែងណាមួយ ដើម្បីធ្វើអោយអាជីវកម្ម នៅកម្ពុជាកាន់តែមានលក្ខណៈប្រកួតប្រជែងឡើយ។
- ទីកន្លែងសំរាប់តំបន់កែឆ្នៃសំរាប់នាំចេញ នៅក្នុងយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ ទាមទារអោយមាននូវការវិភាគស៊ីជំរៅបន្ថែមទៀត។
- ការអភិវឌ្ឍន៍ទេសចរណ៍ ទាមទារអោយមាន ការត្រួតពិនិត្យ ហើយសហគមន៍ដែលរងផលប៉ះពាល់គួរអោយមានការសំរេចចិត្ត ការបណ្ដុះបណ្ដាល និងការកសាង

សមត្ថភាព ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និង ពង្រីកនូវការកាត់បន្ថយភាពក្រីក្រ ។

- រាជរដ្ឋាភិបាលកម្ពុជាគប្បីជួយអាជីវកម្មខ្នាតតូច ជាពិសេសជួយកសិករ តាមរយៈការកំណត់សក្តានុពល ទីផ្សារក្នុងស្រុកនិងទីផ្សារ អន្តរជាតិសំរាប់ផលិតផល នានា ដោយកំណត់អត្តសញ្ញាណ និងកាត់បន្ថយឧបសគ្គ ចំពោះខ្សែសង្វាក់ផ្គត់ផ្គង់ ដោយជួយកែលំអរគុណភាព ផលិតផលតាមរយៈបច្ចេកវិជ្ជាសមស្រប និងលុបបំបាត់ នូវការទាមទារអោយបង់ប្រាក់ក្រៅផ្លូវការ ។
- អាជីវកម្មខ្នាតតូចអាចរួមវិភាគទានចំពោះការកែលំអរ ទីផ្សារនិងកែលំអថ្លៃតាមរយៈសាមគ្គីភាព និង សហ-ប្រតិបត្តិការនៅក្នុងសហគមន៍កាន់តែប្រសើរ ។ អង្គការ មិនមែនរដ្ឋាភិបាលស្ថាប័ន និងក្រុមសហគមន៍នានា គប្បី រួមគ្នាធ្វើការតាមបែបមួយដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីលើកកំពស់ជីវភាពរស់នៅ ។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីរិះរកវិធីដើម្បីការពារ និង បង្កើនចំណែកទីផ្សារនៃផលិតផលនៅក្នុងស្រុក ដូចជា តាមរយៈការជួយបង្កើនគុណភាព និងលើកទឹកចិត្ត ពលរដ្ឋកម្ពុជាអោយទិញផលិតផលក្នុងស្រុក ។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីផ្តល់ពត៌មាន និងគាំទ្រចំពោះ ពលរដ្ឋកម្ពុជាដែលបានចុះកិច្ចសន្យាទៅបំរើការនៅ បរទេស (ដូចជាធ្វើការក្នុងឋានៈជាអ្នកបំរើក្នុងផ្ទះ) លៃយ៉ាងណា កុំអោយមានការរំលោភលើសិទ្ធិរបស់អ្នក ទាំងនោះ ។

## ៣.៤. ការធ្វើអោយប្រសើរឡើងនូវសមត្ថភាព

សមត្ថភាពដើម្បីបញ្ចប់ចក្រនៃភាពក្រីក្រ គឺពឹងផ្អែកមួយភាគធំទៅលើការបង្កើនសមត្ថភាព ក្នុងចំណោមប្រជាពលរដ្ឋ។ NPRS ទទួលស្គាល់ថា នេះទាមទារនូវការប្តេជ្ញាចិត្តរយៈពេលវែង ដើម្បីលើកកំពស់សុខភាព អប់រំ អាហារូបត្ថម្ភ និងទឹកស្អាត និងអនាម័យ។ ការវិនិយោគក្នុងវិស័យទាំងនេះក៏រួមចំណែកដោយផ្ទាល់ ចំពោះគុណភាពនៃជីវិតរបស់ប្រជាជន។

### ៣.៤.១. ការរីកចំរើន

មានការវិវិត្តន៏រីកចំរើនក្នុង**វិស័យសុខាភិបាល** ដោយមានការកសាង និងជួសជុលអគារសុខាភិបាល និងការរៀបចំគោលការណ៏ណែនាំ ផ្នែកគាំពារសុខភាពបឋម ការពង្រីកកម្មវិធី DOTs ការកសាងផែនការយុទ្ធសាស្រ្តសុខាភិបាល ការចាប់ផ្តើមគំរោងទ្រទ្រង់វិស័យសុខាភិបាល និងការកសាងនូវដំណើរការធ្វើផែនការអនុវត្តប្រចាំឆ្នាំរបស់ខេត្ត។ ការត្រួតពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ លើវិស័យសុខាភិបាល គឺជាគំនិតមួយដែលទទួលបានការស្វាគមន៏ ដើម្បីលើកកំពស់ការសំរបសំរួល ក្នុងចំណោមដៃគូវិស័យសុខាភិបាល។

សហគមន៏ NGO តែងតែអបអរសាទរចំពោះការរីកចំរើនរបស់ RGC ក្នុងវិស័យ **អប់រំ** ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះគឺ : ការកសាងហេដ្ឋារចនាសម្ព័ន្ធ សាលារៀនថ្មី ការលើកកំពស់លក្ខខណ្ឌសិក្សា សំរាប់សិស្ស និងកំណើនការចុះឈ្មោះចូលរៀនរបស់សិស្ស។ ដំណើរការ PAP ក្នុងបើទោះបីជាវាមិនឥតខ្ចោះក៏ដោយ បានបង្កើនការផ្តល់ធនធានទៅដល់សាលារៀន។

ដើម្បីលើកកំពស់អាហារូបត្ថម្ភ អនុក្រឹត្យស្តីពីអំបិលអ៊ីយ៉ូដទូទៅ ត្រូវបានអនុម័តនិងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី នៅខែ តុលា ឆ្នាំ ២០០៣។ គ្រាប់ថ្នាំជីវជាតិ A ត្រូវបានចែកចាយនៅក្នុងខេត្តចំនួន ៨។ តែទោះបីជាយ៉ាងនេះក្តី ការប្រើប្រាស់អំបិលអ៊ីយ៉ូដ និងជីវជាតិ A នៅទូទាំងប្រទេស នៅមានកំរិតទាបនៅឡើយ។

បើទោះជាមានការប្រសើរឡើងដូចពោលខាងលើ កម្ពុជាមិនស្ថិតនៅលើផ្លូវដើម្បីសំរេចអោយបាន នូវគោលដៅសុខភាព CMDG ឡើយ។ ទិន្នន័យដែលបានមកពីការអង្កេតលើគ្រួសារនៅទូទាំងប្រទេស បង្ហាញថា អត្រាស្លាប់របស់កុមារ និងអត្រាស្លាប់របស់ទារក អាចមានការកើនឡើងក្នុងទសវត្សរ៏កន្លងមក ក្នុងខណៈដែលស្ថិតិផ្សេងៗទៀតបង្ហាញនូវការធ្លាក់ចុះតិចតួច ពីកំរិតខ្ពស់មក។ ស្ថិតិក្នុងវិស័យអប់រំ មានភាពល្អប្រសើរជាង ដែលបង្ហាញថាកម្ពុជាស្ថិតនៅលើផ្លូវត្រឹមត្រូវ ក្នុងការសំរេចគោលដៅចុះឈ្មោះបឋមសិក្សា CMDG ប៉ុន្តែមិនទាន់សំរេចបានគោលដៅចុះឈ្មោះសិក្សានៅមធ្យមសិក្សារបស់ខ្លួន។[៩]

### ៣.៤.២. បញ្ហា

នៅក្នុងវិស័យអាទិភាពផ្នែកសុខាភិបាល និងអប់រំ RGC បានប្តេជ្ញាចិត្តនឹងបង្កើនការបែងចែកថវិកា និងសង្កត់ធ្ងន់លើការផ្តល់សេវាដល់អ្នកក្រ។ យុទ្ធវិធីនេះ មានសារៈសំខាន់ចំពោះការអភិវឌ្ឍន៏ និងធ្វើលើកំពស់លទ្ធភាពផ្សេងៗ និងត្រូវបានទទួលការស្វាគមន៏ដោយសហគមន៏ NGO។ ជាមួយនឹងការអភិវឌ្ឍន៏ទាំងនេះ ជាការសំខាន់គឺការប្តេជ្ញាចិត្តទាំងនោះ ត្រូវបានប្រែក្លាយអោយទៅជាសកម្មភាពជាក់ស្តែង ក្នុងកំរិតជាមូលដ្ឋានបំផុត នៃការផ្តល់សេវា និងការគាំទ្រ។

---

[9] របាយការណ៏ GSCSD, CMDG : ឧបសគ្គចំពោះមុខ និង ក្របខ័ណ្ឌសកម្មភាព ខែ កក្កដា ឆ្នាំ ២០០៣ ។

ក្នុងវិស័យអប់រំ និងសុខាភិបាល RGC បានប្តេជ្ញាចិត្តនឹងបង្កើនថវិកា និងលើកកំពស់ការគាំទ្រចំពោះការផ្តល់សេវាសាធារណៈ។ សហគមន៍ NGO មានការរីករាយដោយបានឃើញនូវការរីកចំរើនទាំងនេះ និងព្យាយាមសហការជាមួយរដ្ឋាភិបាល ដើម្បីបន្តសំរួលដល់ការរីកចំរើននៅក្នុងវិស័យនេះ។ តែទោះជាយ៉ាងនេះក្តី ការរីកចំរើននេះ ត្រូវបានរារាំងដោយការខកខានមិនបានបើកផ្តល់ហិរញ្ញវត្ថុ ដែលបានសន្យាចំពោះវិស័យទាំងនេះ។

RGC បានកំណត់ច្បាស់ថា ខ្លួនមានផែនការនឹងបង្កើនប្រាក់បៀវត្សរ៍ ដើម្បីដោះស្រាយចំពោះភាពកំសោយនៃការលើកទឹកចិត្តតិចតួចបច្ចុប្បន្ន សំរាប់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។ ទទ្ទឹមនឹងទទួលការស្វាគមន៍ចំពោះការកើនឡើងនេះ គេនឹងមិនអនុញ្ញាតអោយមន្ត្រីរាជការ រកប្រាក់ចំណូលក្រៅពីប្រាក់ខែរបស់គេនោះឡើយ។ NGO ស្នើថា ក្នុងវិស័យទាំងឡាយដូចជា សុខាភិបាលត្រូវមានការទទួលស្គាល់ការធ្វើការក្រៅម៉ោងរបស់មន្ត្រីរាជការ និងកំណត់អោយបានកាន់តែប្រសើរ ហើយការលើកទឹកចិត្ត បន្ថែមដែលផ្តល់ជូនដោយហិរញ្ញវត្ថុម្ចាស់ជំនួយត្រូវធ្វើអោយទៅជាស្តង់ដារ។ គេអាចស្នើអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុស្រាយបំភ្លឺ តើប្រាក់ឧបត្ថម្ភ និងការលើកទឹកចិត្តបន្ថែម អាចធ្វើទៅតាមច្រក PAP បានយ៉ាងដូចម្តេច។

នៅក្នុង**វិស័យសុខាភិបាល** ការចំណាយត្រូវតំរង់ទិសចំពោះកិរិតប្រតិបត្តិថ្នាក់ក្រោម។ ប៉ុន្មានឆ្នាំកន្លងមកនេះ ធនធានជាច្រើន ត្រូវបានផ្តល់ទៅដល់សកម្មភាពនៅថ្នាក់លើ ដូចជា ការស្រាវជ្រាវ និងនិងការកសាងយុទ្ធសាស្ត្រ។ ជំនួយចំពោះវិស័យសុខាភិបាលដែលទទួលបានពីខាងក្រៅ ត្រូវផ្តោតការយកចិត្តទុកដាក់តិចតួចលើមុខជំងឺមួយចំនួន" ដែលតែងកើត "ហើយផ្តោតអោយបានច្រើនលើការបង្កាជំងឺ អាហារូបត្ថម្ភ និងសុខភាពមាតា និងកុមារ។ បន្ទប់ព្យាបាលនៅជនបទ និងបន្ទប់ព្យាបាលនៅទីក្រុង បានបង្ហាញអោយឃើញនូវប្រសិទ្ធភាពចំណាយយ៉ាងខ្លាំង។

ទទ្ទឹមនឹងនេះ ផ្នែកសុខាភិបាលឯកជន ដែលមានចំណែកយ៉ាងធំក្នុងការពិគ្រោះយោបល់ពេទ្យ ជាពិសេសនៅទីក្រុង តំរូវអោយមានបទប្បញ្ញត្តិច្បាស់លាស់ និងមានប្រសិទ្ធភាព ដើម្បីធានានូវការប្រតិបត្តិវិជ្ជាជីវៈពេទ្យត្រឹមត្រូវ។

NGOs ស្វាគមន៍នូវការកសាងក្របខ័ណ្ឌ យុទ្ធ-សាស្ត្រសំរាប់មូលនិធិសមធម៌ របស់ក្រសួងសុខាភិបាល ដើម្បីផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃដល់អ្នកក្រ។ NGOs រង់ចាំបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយក្រសួងក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។

ការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រក្នុងការបង្កើន និងលើកកំពស់ការផ្តល់សេវាសុខភាព ក្នុងវិស័យជាក់លាក់មួយចំនួនគឺមានសារៈសំខាន់។ ជាពិសេស ត្រូវផ្តល់អាទិភាពទៅដល់គោលដៅ ទាំងនៅក្នុង NPRS និង CMDG ស្តីពីទារកពោលគឺអត្រាស្លាប់របស់កុមារក្រោមអាយុប្រាំឆ្នាំ និងអត្រាស្លាប់មាតា។ នេះទាមទារអោយមានទាំងការធ្វើអោយប្រសើរឡើងនូវការគាំពារសុខភាពបន្តពូជ និងការខិតខំប្រឹងប្រែងដើម្បីធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភ។

នៅក្នុងវិស័យ**អប់រំ** ការធ្វើអោយប្រសើរឡើងនូវកំរិតនៃការចុះឈ្មោះចូលរៀន ត្រូវបានទទួលការស្វាគមន៍ ប៉ុន្តែអត្រាត្រួតថ្នាក់ និងបោះបង់ចោលការសិក្សា នៅតែមានកំរិតខ្ពស់។ ទាមទារអោយមានយុទ្ធសាស្ត្រសំដៅកែប្រែទាំងនៅលើតំរូវការ និងការផ្គត់ផ្គង់ ដើម្បីធានានូវការទទួលបានដោយសមធម៌របស់ក្មេងស្រី ដែលមានអត្រាចុះឈ្មោះទាប និងអត្រារៀនបន្តទាប និងសំរាប់បញ្ចូលកុមារពិការ និងជនជាតិភាគតិច ទៅក្នុងប្រព័ន្ធសាលារដ្ឋ។

គ្រូមានចំនួនខ្វះយ៉ាងច្រើន នៅក្នុងតំបន់ដាច់ស្រយ៉ាលនៃប្រទេស ដែលមានអត្រាសិស្ស/គ្រូ លើសពី ៧០:១ ក្នុងខេត្តមួយចំនួន។ យុទ្ធសាស្ត្រដាក់ពង្រាយគ្រូ មិនមានប្រសិទ្ធភាពឡើយ ដោយសារកង្វះការលើកទឹកចិត្ត និងឧបសគ្គផ្សេងៗទៀត។ ទាមទារអោយមានការខិតខំបន្ថែមទៀត ដើម្បីជ្រើសរើស និងបណ្តុះបណ្តាលគ្រូដែលរស់នៅមូលដ្ឋាននោះតែម្តង។

សហគមន៍ NGO ស្វាគមន៍ការដាក់ចេញនូវ**ផែនការសកម្មភាពអាទិភាព** (PAP) និងការផ្សព្វផ្សាយគោលដៅសំរាប់ការបើកផ្តល់ហិរញ្ញវត្ថុ ថាជាការវិវត្តន៍មួយដ៏សំខាន់ឆ្ពោះទៅរកការកសាងនូវប្រព័ន្ធមួយ នៃការផ្តល់ហិរញ្ញវត្ថុដោយចំហ និងមានប្រសិទ្ធភាព។ ទាំងនៅក្នុងវិស័យសុខាភិបាល និងអប់រំ បញ្ហានៃការបែងចែកហិរញ្ញវត្ថុចំពោះផ្នែកសាធារណៈ ធ្លាប់ជា និងបន្តជាកត្តាចំបងមួយចំពោះសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីផ្តល់សេវាទាំងនេះប្រកបដោយប្រសិទ្ធភាព និងសមធម៌។

ទន្ទឹមនឹងអបអរសាទរប្រព័ន្ធ PAP នៃការបែងចែកថវិកាដែលត្រូវធ្វើសវនកម្មតាមក្រោយ NGO កត់សំគាល់ឃើញថា ជាការគួរអោយសោកស្តាយដែលមានភ័ស្តុតាងតិចតួច ក្នុងការបញ្ជាក់ថា ប្រព័ន្ធនេះមានផលប៉ះពាល់សំខាន់ក្នុងការអនុវត្តថវិកា ក្នុងវិស័យសុខាភិបាល និងអប់រំ។ បញ្ហានៃការគ្រប់គ្រងសាច់ប្រាក់ នៅតែបន្តកើតឡើង ដោយការបើកផ្តល់ប្រាក់មានភាពមិនទៀងទាត់ និងយឺតយ៉ាវ ទំនងជាបើកថវិកាថយក្រោយវិញ។

ក្នុង**វិស័យអប់រំ**មានការបើកផ្តល់ ៨០% នៃវិភាជន៍ PAPឆ្នាំ ២០០២ និងគ្មានការបើកផ្តល់ប្រាក់វិភាជន៍ PAP ២០០៣ឡើយ គិតមកដល់ខែ តុលា ឆ្នាំ ២០០៣។ ប្រការនេះកំពុងបង្ក ការខូចខាតយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពនៃវិស័យអប់រំ ក្នុងការគោរពតាមការប្តេជ្ញាចិត្តរបស់ខ្លួន។ ដែលផលវិបាកមួយផ្នែកនៃបញ្ហានេះគឺ សាលារៀន និងគ្រូបង្រៀន នៅតែរកប្រាក់ក្រៅផ្លូវការពីសិស្សរបស់ខ្លួន ដែលនាំអោយមានការ ក៏រិតចំពោះការបានទទួលនូវការអប់រំសំរាប់គ្រួសារក្រីក្រ។

ក្នុងវិស័យសុខាភិបាល ក៏ដូចជាវិស័យផ្សេងៗទៀតដែរ នៅតែបន្តមានបញ្ហាជាមួយ " រដូវប្រាំង" នៃថវិកា ដោយហេតុថា មូលនិធិមិនត្រូវបានផ្តល់ជូនប្រកបដោយប្រសិទ្ធភាព និងទៀងទាត់ចំពោះផ្នែកនេះ។ ហេតុនេះ ក្នុងកំឡុងពេល ៦ ខែដំបូងនៃឆ្នាំ បុគ្គលិកដែលបំរើការនៅតាមមូលដ្ឋានតែងតែជួបប្រទះបញ្ហាយ៉ាងធ្ងន់ធ្ងរ ក្នុងការទទួលបានថវិការបស់ខ្លួន ដែលជាហេតុធ្វើអោយពួកគេគ្មានលទ្ធភាពផ្តល់សេវាសុខភាពប្រកបដោយប្រសិទ្ធភាព។ កង្វះខាតទឹកប្រាក់ដែលអាចរកបាន នៅក្នុងកំឡុងពេលនេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការផ្តល់សេវាសុខភាព។

### ៣.៤.៣. អនុសាសន៍

សហគមន៍ NGO គួរស្នើឡើងនូវអនុសាសន៍ដូចខាងក្រោមនេះ ជុំវិញវិស័យសុខាភិបាល អប់រំ និងអាហារូបត្ថម្ភ:

- RGC ត្រូវធានានូវតម្លាភាព ភាពដែលអាចទស្សន៍ទាយបាន និងគណនេយ្យភាព ក្នុងការបែងចែក និងការបើកផ្តល់ថវិកា។ សំរេចបាននូវគោលដៅទាំងនេះ មិនត្រឹមតែទាមទារនូវជំនួយបច្ចេកទេសប៉ុណ្ណោះទេ តែថែមទាំងឆន្ទៈនយោបាយ។
- ប្រាក់ខែ និងរង្វាន់លើកទឹកចិត្តសំរាប់បុគ្គលិក ដែលបំរើការនៅក្នុងវិស័យសុខាភិបាល និង អប់រំ ត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងចំណាយក្នុងការរស់នៅ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ដើម្បីធានាមិនអោយមានការយកកំរៃក្រៅផ្លូវការ។ កំរៃទាំងនេះ ត្រូវបានទទួលស្គាល់ថា មាន

ផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងមកលើអ្នកក្រ ដែលធ្វើអោយមហន្តរាយដល់លទ្ធភាពរបស់ពួកគេ ក្នុងការទទួលបាននូវសេវា ដែលនឹងជួយកាត់បន្ថយ បញ្ហាទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងភាពក្រីក្រ ។

- ដើម្បីបង្កើនចំនួនគ្រូបង្រៀននៅតាមតំបន់ជនបទដាច់ស្រយ៉ាល ត្រូវមានប្រើប្រាស់អោយ កាន់តែទូលំទូលាយនូវគ្រូបង្រៀនជាប់កិច្ចសន្យាដែលរស់នៅ មូលដ្ឋាននោះផ្ទាល់ ដោយផ្ដល់អោយពួកគេនូវឱកាសសំរាប់ការបណ្ដុះបណ្ដាល និងលើកកំពស់សមត្ថភាព ដើម្បីអោយពួកគេមានក្ដីសង្ឃឹមខ្លះក្នុងការចូលទៅក្នុងសេវាបង្រៀនអចិន្ត្រៃយ៍ ។ ថ្នាក់សំរាប់ចូលរៀនគរុកោសល្យ គួរបន្ទាបសំរាប់សិស្សដែលបានបញ្ចប់ថ្នាក់ទី ៩ នៅតាមស្រុក ដែលគ្មានវិទ្យាល័យ ។
- ដើម្បីធានាថា អ្នកក្រត្រូវបានផ្ដោតគោលដៅ៧ MDG សំរាប់សុខាភិបាល ត្រូវបំពេញបន្ថែមដោយគោលដៅសំរាប់ស្រទាប់ ដែលក្រីក្របំផុតនៃសង្គម ។ ការផ្ដល់ទាំងសេវាសុខាភិបាល និងអប់រំដោយផ្នែកឯកជនត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ដោយសង្គមស៊ីវិល និងរដ្ឋាភិបាលទាំងអស់គ្នា ។
- ត្រូវធ្វើវិភាជន៍ធនធានបន្ថែមទៀត ចំពោះគំរោងទាំងឡាយ សំដៅបង្កាជំងឺ និង អាហារូបត្ថម្ភ ជាជាងការកសាងគោលនយោបាយ ។

## ៣.៥. ការពង្រឹងស្ថាប័ននិងលើកកំពស់អភិបាលកិច្ច

កំណែទំរង់ស្ថាប័ន និងការលើកកំពស់អភិបាលកិច្ច គឺជាចំណុចសំខាន់នៃសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីអនុវត្ត NPRS ។ ការប្តេជ្ញាចិត្តដើម្បីកាត់បន្ថយអំពើពុករលួយ និងការពង្រឹងលទ្ធិប្រជាធិបតេយ្យមានសារៈសំខាន់ ចំពោះប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី និងគំរោងផ្សេងៗទៀត ។ ការកើតមានអំពើពុករលួយនៅគ្រប់ជាន់ថ្នាក់ នៅក្នុងរដ្ឋាភិបាល និងសង្គមកម្ពុជា ធ្វើអោយខូចខាតដល់សមត្ថភាពរបស់ស្ថាប័ន និងបុគ្គលិករបស់ខ្លួនដើម្បីអនុវត្តកំណែទំរង់ និងការផ្លាស់ប្តូរ ។

### ៣.៥.១. ការរីកចំរើន

កាលពី ខែ មិថុនា ឆ្នាំ ២០០៣ សេចក្តីព្រាងច្បាប់**ប្រឆាំងអំពើពុករលួយ** ត្រូវបានបញ្ជូនទៅសភាជាតិ។ មួយផ្នែកដោយសារស្ថានភាពជាប់គាំងផ្នែកនយោបាយនៅតែបន្តសេចក្តីព្រាងច្បាប់នេះនៅមិនទាន់ត្រូវបានអនុម័តនៅឡើយ ។

**កាលពីខែ កក្កដា ឆ្នាំ ២០០៣** ការបោះឆ្នោតជ្រើសរើសសភាជាតិត្រូវបានរៀបចំឡើង ។ បើទោះបីជាមានការលើកឡើងពីកង្វល់ជុំវិញការបំភិតបំភ័យ និងភាពមិនប្រក្រតីក៏ដោយ អ្នកសង្កេតការណ៍ភាគច្រើនបានសន្និដ្ឋានថា ការអនុវត្តបច្ចេកទេសទៅលើការបោះឆ្នោត មានការរីកចំរើនច្រើនជាងការបោះឆ្នោតកន្លងមក ។ ស្ថានភាពជាប់គាំងនយោបាយបច្ចុប្បន្នបន្ទាប់ពីការបោះឆ្នោត គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតចំពោះកំណែទំរង់អភិបាលកិច្ច ។

ឆ្នាំ ២០០៣ ក៏បានសង្កេតឃើញនូវការកសាង និងផ្សព្វផ្សាយយុទ្ធសាស្ត្រកំណែទំរង់ច្បាប់ និង តុលាការផងដែរ ។ បច្ចុប្បន្ននេះ សាលាភូមិន្ទចៅក្រម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលចៅក្រមកំពុងដំណើរការ ។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងក្រមស៊ីវិល និងក្រមព្រហ្មទណ្ឌ កំពុងត្រូវបានធ្វើការកែប្រែឡើងវិញ ។

ការរីកចំរើនក្នុង**វិមជ្ឈការ** ត្រូវបានបំផ្លិចបំផ្លាញដោយការខកខានរបស់រដ្ឋបាលកណ្តាល មិនបានផ្ទេរថវិកាទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ទោះបីជាយ៉ាងនេះក៏ដោយ ឃុំ-សង្កាត់ភាគច្រើន បានកសាងផែនការអភិវឌ្ឍន៍និងវិនិយោគ តាមទំរង់មួយដែលមានការចូលរួមកាន់តែច្រើន ។

### ៣.៥.២. បញ្ហា

បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ កាលពីខែ កក្កដា ឆ្នាំ ២០០៣ ការជាប់គាំងនយោបាយ មានន័យថា ការរីកចំរើនឆ្ពោះទៅរកកំណែទំរង់ស្ថាប័ន និងការលើកកំពស់អភិបាលកិច្ច ត្រូវបានផ្អាកសិន ។ ការខកខានមិនបានផ្តល់នូវការគ្រប់គ្រងមួយដែលមានស្ថេរភាព មិនត្រឹមតែបង្ហាញពីការបំផ្លាញលើគ្រប់វិស័យកំណែទំរង់ ប៉ុន្តែក៏វានាំទៅរកការបំផ្លាញអភិបាលកិច្ចខ្លួនឯងផងដែរ ។

ជាទូទៅ ការបោះឆ្នោតជ្រើសរើសសភាជាតិឆ្នាំ ២០០៣ ត្រូវបានចាត់ទុកថា មានការរៀបចំល្អប្រសើរជាងឆ្នាំមុនៗ ។ ទោះជាយ៉ាងនេះក្តី នៅមានកង្វល់ធ្ងន់ធ្ងរជាច្រើនពាក់ព័ន្ធនឹងដំណើរការរបស់ NEC និងភ្នាក់ងារក្រោមបង្គាប់របស់ខ្លួន នៅថ្នាក់ឃុំ-សង្កាត់ និងថ្នាក់ខេត្ត-ក្រុង ។ ការកែទំរង់ភ្នាក់ងារទាំងនេះ និងការបន្តកសាងសមត្ថភាព ត្រូវតែចាត់ទុកថា ជាដំណើរការដែលនៅតែបន្ត ជាជាងជាបញ្ហាមួយ ដែលត្រូវដោះស្រាយ តែនៅពេលដែលឈានជិតដល់ការបោះឆ្នោតអោយសោះ ។ ការធ្វើអោយប្រសើរឡើងនូវការកសាងសមត្ថភាព និងការខិតខំប្រឹងប្រែងឥតស្រាកស្រាន្តដើម្បីធានានូវឯករាជ្យភាពរបស់មន្ត្រី គឺមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្ត ក្នុងការរៀបចំការបោះឆ្នោត

នាពេលអនាគត ជាពិសេសការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។

NPRS ទទួលស្គាល់ថា បញ្ហាអំពើពុករលួយ មានសារៈសំខាន់ចំពោះរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ នៅក្នុងទសវត្សរ៍កន្លងមក កិច្ចខិតខំប្រឹងប្រែងដើម្បីអនុម័ត **ច្បាប់ប្រឆាំងអំពើពុករលួយ** ត្រូវបានជាប់គាំងជាច្រើនដង ហើយនៅពេលថ្មីៗនេះ ដោយការខកខានក្នុងការបង្កើតរដ្ឋាភិបាលមិនបាន បន្ទាប់ពីការបោះឆ្នោតខែ កក្កដា សេចក្តីព្រាងច្បាប់ត្រូវកែកែប្រែឡើងវិញ និងពិភាក្សាដោយសមាជិកសភាថ្មី មុននឹងអនុម័តសេចក្តីព្រាងច្បាប់នេះ ដើម្បីពង្រឹងនូវការកំណត់និយមន័យអំពើពុករលួយ។

**កំណែទំរង់យុត្តិធម៌** មានសារៈសំខាន់ចំពោះការកាត់បន្ថយអំពើពុករលួយ និងដោះស្រាយចំពោះនីរទណ្ឌភាព នៅក្នុងសង្គមកម្ពុជា។ តុលាការមួយដែលខ្សោយ និងការខ្វះនីតិរដ្ឋ ធ្វើអោយអន្តរាយដល់វិនិយោគនៅក្នុងប្រទេស និងកិច្ចខិតខំប្រឹងប្រែងសំរេចអោយបាននូវយុត្តិធម៌ សំរាប់អ្នកក្រ និងការកាត់បន្ថយភាពក្រីក្រ។ ការអនុម័តកម្មវិធីកំណែទំរង់វិស័យយុត្តិធម៌ ត្រូវបានទទួលស្វាគមន៍ថា ជាជំហានទីមួយឆ្ពោះទៅរកការពង្រឹងស្ថាប័នគតិយុត្តិ។ ទោះជាយ៉ាងនេះក្តី ការរីកចំរើននៅក្នុងឆ្នាំ ២០០៣ ទាំងមូល នៅមានកំរិតនៅឡើយ។ កំណែទំរង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ នឹងមានសារៈសំខាន់ចំពោះ កំណែទំរង់តុលាការ។

**កំណែទំរង់មន្ត្រីរាជការ នៅតែជាអាទិភាពចំបង។** ការលុបបំបាត់អំពើពុករលួយនៅក្នុងមន្ត្រីរាជការ ត្រូវមានវិធានការជាច្រើន រួមមានទាំងការរារាំងមនុស្សមិនអោយទិញមុខតំណែងជាដើម។ ការបង្កើនប្រាក់ខែសំរាប់មន្ត្រីរាជការ មានសារៈសំខាន់ចំពោះ ការធ្វើអោយប្រសើរឡើងនូវការផ្តល់សេវា ហើយត្រូវតែដោះស្រាយតែម្តង។ ក៏ប៉ុន្តែនេះត្រូវមានការគាំទ្រ ដោយការបង្កើនសមត្ថភាពមន្ត្រីទាំងនោះ និងប្រព័ន្ធស្អាតស្អំមួយក្នុងការគ្រប់គ្រង ការវិវត្តន៍ក្នុងវិជ្ជាជីវៈ និងការឡើងថ្នាក់ដោយផ្អែកលើមូលវិចារណ៍។

**វិមជ្ឈការ** បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ជាលើកដំបូង នាំអោយមានការរីកចំរើនល្អ និងត្រូវបានទទួលស្វាគមន៍ជាទូទៅ ដោយសហគមន៍ NGO។ សមិទ្ធផលទាំងឡាយ ដូចជាការពង្រឹងការគាំទ្រចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ និងការកសាងឧបករណ៍ច្បាប់ដែលត្រូវការខ្លាំងបំផុត ត្រូវតែធ្វើបន្ត។ ប្រការនេះទាមទារអោយមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ សំរាប់ក្រុមប្រឹក្សា ឃុំ-សង្កាត់។

សហគមន៍ NGO អបអរសាទរចំពោះសកម្មភាពដែលត្រូវបានអនុវត្តមួយផ្នែកនៃកម្មវិធីសីលា។ បើទោះបីជាផលវិបាកនៃសកម្មភាពទាំងនេះ ហាក់មានការប្រែប្រួលខុសៗគ្នាក៏ដោយ កម្មវិធីនេះមានផលវិបាកជាវិជ្ជមានក្នុងការសំរួលដល់ការបង្វែរថវិកា និងធនធានទៅថ្នាក់ឃុំ-សង្កាត់។

ទោះជាយ៉ាងនេះក្តី មិនទាន់មានការដាក់អោយអនុវត្តនូវវិធានការណាមួយ ដើម្បីកំណត់ថា គំរោងដែលត្រូវបានកំណត់តាមរយៈដំណើរការដែលមានការចូលរួម គឺជាគំរោងដែលនឹងមានផលវិបាកខ្លាំងក្លាបំផុត មកលើការកាត់បន្ថយភាពក្រីក្រទេ។ ការពង្រឹងប្រព័ន្ធវិមជ្ឈការនៃការធ្វើសេចក្តីសំរេចចិត្ត ត្រូវទៅស្របគ្នានឹងការយល់ដឹងមួយថា ប្រជាធិបតេយ្យមូលដ្ឋាន ត្រូវតែដាក់បញ្ចូលទៅក្នុងការធ្វើសេចក្តីសំរេចិត្តថ្នាក់កណ្តាល។ បទពិសោធន៍របស់សហគមន៍ក្នុងការកំណត់ និងផ្តល់ពតិមាន អាចនាំទៅរកការកំណត់អាទិភាពគំរោងទ្រទ្រង់អ្នកក្របន្ថែមទៀត និងជាផ្នែកមួយសំខាន់ នៃការពង្រឹងប្រព័ន្ធគ្រប់គ្រងថ្នាក់មូលដ្ឋាន និងថ្នាក់កណ្តាល។

### ៣.៩.៣. អនុសាសន៍

សហគមន៍ NGO ស្នើឡើងនូវអនុសាសន៍ដូចខាងក្រោម ជុំវិញកំណែទំរង់អភិបាលកិច្ច និងស្ថាប័នៈ

- ច្បាប់ប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាពមួយ ត្រូវតែកសាងឡើង អនុម័ត និងអនុវត្ត ជាករណីមួយអាទិភាព។ ទាមទារនូវឆន្ទៈនយោបាយមួយដ៏ពិតប្រាកដ ដើម្បីធានាថាវិធានការប្រឆាំងអំពើពុករលួយនានា មិនត្រូវបានពន្យារពេលទៀតឡើយ។ កិច្ចសហប្រតិបត្តិការ ប្រឆាំងអំពើពុករលួយនៅគ្រប់ជាន់ថ្នាក់ មានសារៈសំខាន់ដើម្បីដោះស្រាយនូវភាពកំសោយជាមូលដ្ឋាន ទាំងអភិបាលកិច្ច និងសេដ្ឋកិច្ចនៅកម្ពុជា។
- ច្បាប់ផ្សេងទៀតដែលទាមទារអោយមានការអនុម័ត ដោយសភាជាតិ និងព្រឹទ្ធសភានៅពេលដ៏ខ្លីខាងមុខនេះ រួមមានក្រមព្រហ្មទណ្ឌ ក្រមស៊ីវិល ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និង ច្បាប់ប្រឆាំងការជួញដូរ។
- គណៈកម្មការឯករាជ្យមួយប្រឆាំងអំពើពុករលួយ ត្រូវបង្កើតឡើង និងតាមដានត្រួតពិនិត្យច្បាប់ និងវិធានការប្រឆាំងអំពើពុករលួយ។
- ការបង្កើនប្រាក់ខែសំរាប់មន្ត្រីរាជការមានសារៈ សំខាន់ និងត្រូវតែដោះស្រាយជាករណីអាទិភាព ទោះជាយ៉ាងនេះក្តី នេះត្រូវមានការគាំទ្រក្នុងការបង្កើនសមត្ថភាពចំពោះមន្ត្រីទាំងនោះ និងប្រព័ន្ធច្បាស់លាស់មួយក្នុងការត្រួតពិនិត្យ ការឡើងមុខតំណែងក្នុងវិជ្ជាជីវៈ និងការតំលើងមុខតំណែងដោយផ្អែកតាមមូលវិចារណ៏។
- RGC ត្រូវដោះស្រាយនូវទំហំ និង រចនាសម្ព័ន្ធមន្ត្រីរាជការ និងការជ្រើសរើស ប្រាក់ខែ ការបណ្តុះបណ្តាល និងការវាយតំលៃបុគ្គលិកជាករណីបន្ទាន់មួយ។ ដើម្បីធ្វើដូចនេះបាន RGC គួរធានាថា បុគ្គលិកសុខាភិបាល និងគ្រូបង្រៀនដែលមាន សមត្ថភាព និងអ្នកប្រកបវិជាជីវៈផ្សេងៗទៀត កាន់តែបំរើសេវាបានល្អនៅក្នុងតំបន់ជនបទ។
- គួរកសាងគំរោងរបស់ឃុំ-សង្កាត់ ដោយមានការផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ លើការទ្រទ្រង់អ្នកក្រ។ ក្រុមប្រឹក្សាឃុំ-សង្កាត់គួរ បង្កើតនូវប្រព័ន្ធទាំងឡាយជាមួយដៃគូ ដើម្បីវាយតំលៃពីផលប៉ះពាល់នៃវិមជ្ឈការមកលើ ការកាត់បន្ថយភាពក្រីក្រ
- ត្រូវដាក់អោយមាន នូវយន្តការសវនកម្មសំរាប់មូលនិធិឃុំ-សង្កាត់។ កំណែទំរង់តាមបែបវិមជ្ឈការមិនត្រូវផ្តោតតែលើការធ្វើផែនការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការលើកកំពស់ និង បញ្ចូលមកក្នុងស្ថាប័ននូវទស្សនាទានដូចជា តម្លាភាព និងគណនេយ្យភាពសាធារណៈ ដើម្បី កសាងសមត្ថភាពសំរាប់វិមជ្ឈការសារពើពន្ធ។
- យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រត្រូវអោយមាន ការអនុវត្តន៍និងការតាមដានប្រកបដោយប្រសិទ្ធភាព។ អ្នករៀបចំគោលនយោបាយនៅក្នុង ក្រសួងពាក់ព័ន្ធចាំបាច់ត្រូវធ្វើផែនការសកម្មភាព ដោយផ្អែកលើលទ្ធផលនៃការតាមដានបែបនេះ រួមមានការតាមដានដោយ PMATU និង NIS។
- អភិបាលកិច្ចល្អអាចត្រូវបានលើកកំពស់ តាមរយៈការលើកទឹកចិត្តអោយមានការចូលរួមរបស់ អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងក្រុម សង្គមស៊ីវិលនានានៅក្នុងការកសាងផែនការ ការអនុវត្ត ការតាមដាន និងការវាយតំលៃនៃកម្មវិធីអភិវឌ្ឍន៍។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីលៃយ៉ាងណាអោយសាធារណៈជនមានលទ្ធភាពទទួលពត៌មានរបស់

រដ្ឋាភិបាល តាមរយៈការណែនាំអោយមាន លទ្ធភាពទទួលច្បាប់ពតិមាន ដែលសេចក្តីព្រាងត្រូវបានធ្វើតាមបែបមួយដែលមានការចូលរួម ។

- សភាជាតិ គប្បីពិនិត្យមើលសារឡើងវិញនូវបញ្ហានានាដែលពាក់ព័ន្ធនឹងការបង្កើតរដ្ឋាភិបាលថ្មី ដើម្បីបង្កាកុំអោយបញ្ហាបែបនេះកើតមាន សារជាថ្មីក្នុងពេលបោះឆ្នោតនាពេលអនាគត ។ គេអាចពិចារណាអំពីលទ្ធភាពក្នុងការកែប្រែរដ្ឋធម្មនុញ្ញ សំរាប់បង្កើតរដ្ឋាភិបាលថ្មី ។

## ៣.៦.ការកាត់បន្ថយភាពងាយរងគ្រោះ

NPRS បញ្ចូលពាក្យខាងក្រោមចំណងជើង " ការកាត់បន្ថយភាពដែលងាយរងគ្រោះ " : សន្តិសុខស្បៀង ការជួញដូរមនុស្ស HIV/AIDS ការគ្រប់គ្រងគ្រោះមហន្តរាយ កំចាត់មីន ការគ្រប់គ្រងបរិស្ថាន ជនជាតិភាគតិច និងយែនឌ័រ។ ចំពោះបញ្ជីឈ្មោះនេះ NGOs សូមបន្ថែមពិការភាព និងការធ្វើនីតិសម្បទា ការកាត់បន្ថយអាវុធធុនស្រាល សិទ្ធិរបស់កុមារនិងមនុស្សចាស់ និង សិទ្ធរបស់ប្រជាជនដែលជួបប្រទះនូវការរុះរើទីតាំងដោយបង្ខំ។

បើទោះបីជាមាននិយាយក្នុង NPRS ក៏ដោយ ប្រសិនបើម្ចាស់ជំនួយធំៗផ្តោតការយកចិត្តទុកដាក់តិចតួច លើសុខាភិបាល អប់រំ កសិកម្ម និងការអភិវឌ្ឍន៍ជនបទ នឹងនៅមានគ្រោះថ្នាក់ គឺបញ្ហាភាពដែលងាយរងគ្រោះ នឹងមិនត្រូវបានដោះស្រាយដោយស្មើភាពឡើយ។ វិស័យជាច្រើនដែលមានសារៈសំខាន់ ចំពោះការកាត់បន្ថយភាពដែលងាយរងគ្រោះថ្នាក់ ត្រូវបានដកចេញតាំងពីដំបូង ពីលក្ខខណ្ឌនៃការធ្វើរបាយការណ៍ សំរាប់របាយការណ៍លើកទីមួយ ស្តីពីការរីកចំរើនរបស់ NPRS។ បញ្ហាជាច្រើនក្នុងចំណោមបញ្ហាទាំងនេះ ត្រូវបានដោះស្រាយដោយក្រសួង និងស្ថាប័នតូចតាច ដែលខ្វះខាតធនធានដើម្បីបំពេញតួនាទីរបស់គេ។

### ៣.៦.១. ការរីកចំរើន

ម៉ាទ្រីសនៃសេចក្តីព្រាងរបាយការណ៍ ស្តីពីការរីកចំរើនរបស់ NPRS បង្ហាញថា នៅឆ្នាំ ២០០៣ MOSALVY ខកខានមិនសំរេចបាននូវគោលដៅនៃការការពារផ្នែកសង្គម ដោយសារកង្វះខាតហិរញ្ញវត្ថុ ជាពិសេសចំពោះសកម្មភាពការពារកុមារ។

វិស័យពិការភាព និងការធ្វើនីតិសម្បទា ក៏ទទួលការកាត់បន្ថយជំនួយរបស់ម្ចាស់ជំនួយដែរ ដែលនាំទៅដល់ការកាត់បន្ថយចំនួនមជ្ឈមណ្ឌលធ្វើនីតិសម្បទារូបវ័ន្តជាច្រើន ពី ១៦ នៅឆ្នាំ ២០០១ មក ១២ នៅឆ្នាំ ២០០៣។ ច្បាប់ស្តីពីការភាពត្រូវបានព្រាង ដោយមានគោលបំណងធានាអោយជនពិការទទួលបាននូវសេវា និងកម្មវិធីអភិវឌ្ឍន៍។

បើទោះបីជា NPRS ស្នើអោយមានការស្រាវជ្រាវលើសហគមន៍ជនជាតិភាគតិច ដើម្បីកំណត់ពីតំរូវការរបស់ពួកគេក៏ដោយ ក្រសួងអភិវឌ្ឍជនបទនៅតែរង់ចាំការគាំទ្រពីម្ចាស់ជំនួយដើម្បីចាប់ផ្តើមការស្រាវជ្រាវនេះ។

MOWVA លើកកំពស់ការបញ្ចូលយែនឌ័រ តាមរយៈការបណ្តុះបណ្តាលមនុស្ស និងជំរុញការវិភាគយែនឌ័រនៅក្នុងក្រសួងចំនួន ១៦។

ផែនការសកម្មភាពប្រាំឆ្នាំស្តីពីការកំចាត់មីន ២០០៣-២០០៧ និងយុទ្ធសាស្ត្រ ត្រូវបានកសាងឡើង ហើយបានធ្វើសេចក្តីព្រាងផែនការជួយដល់ជនរគ្រោះដោយសារមីន។ នៅឆ្នាំ ២០០៣ ផ្ទៃដីចំនួន ២.៨០០ហិកតា ត្រូវបានកំណត់ដើម្បីបោសសំអាតមីន ដែលតាមការប៉ាន់ស្មាន នឹងផ្តល់ផលប្រយោជន៍ដល់ ៨៥.០០០ គ្រួសារ។

MAFF បានពង្រីក និងជំរុញកម្មវិធីពិសេសអំពីសុវត្ថិភាពស្បៀង និងបានចាប់ផ្តើមរៀបចំនូវប្រព័ន្ធ កំណត់ពត៌មាន នៃភាពដែលងាយរងគ្រោះដោយសារអសន្តិសុខស្បៀង។ គេរំពឹងថានឹងមានការគាំទ្របន្ថែមទៀត ចំពោះការលើកកំពស់អាហារូបត្ថម្ភ តាមរយៈគំរោងគាំទ្រវិស័យសុខាភិបាល។

MOE បានបន្តកម្មវិធីធានានូវការអភិវឌ្ឍន៍ ប្រកបដោយចីរភាព នូវតំបន់ឆ្នេរ ដោយលើកកំពស់សមត្ថភាពរបស់ខ្លួន ក្នុងការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និងបង្កើត

គណៈកម្មាធិការសំរបសំរួលថ្នាក់ជាតិ អំពីសារធាតុបំពុលសរីរាង្គ។

## ៣.៦.២. បញ្ហា

ភាពក្រីក្រមានផលវិបាកដ៏ធំមកលើជីវិតរបស់ស្ត្រី និងកុមារ។ ពួកគេជួបប្រទះនូវការរំលោភបំពានសិទ្ធិធ្ងន់ធ្ងរជាច្រើននៅកម្ពុជា ដូចជា អំពើហិង្សាក្នុងគ្រួសារ ការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ និងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច កើតចេញមកពី ទំនាក់ទំនងផ្នែកយែនឌ័រដែលមានវិសមភាព និងដែលកាន់តែមានលក្ខណៈធ្ងន់ធ្ងរបន្ថែមទៀត ដោយសារភាពក្រីក្រ។

សហគមន៍ NGO ជឿថា យែនឌ័រមិនអាចត្រូវបានចាត់ទុកថាជាបញ្ហាតាមផ្នែកបានឡើយ។ ជាការសំខាន់ គឺរដ្ឋាភិបាល ម្ចាស់ជំនួយ និង NGOs ទាំងអស់គ្នា មើលឃើញបញ្ហាយែនឌ័រ ជាបញ្ហាដែលមានទំនាក់ទំនងគ្នា។ ការកសាងនូវទិន្នន័យបញ្ហាពាក់ព័ន្ធនឹងយែនឌ័រជាផ្នែកៗ សំរាប់គ្រប់វិស័យទាំងអស់ មានសារៈសំខាន់ទៅបាន លុះត្រាតែមានការផ្លាស់ប្តូរជាច្រើនក្នុងការយល់ដឹង និងសកម្មភាពលើបញ្ហាយែនឌ័រ។

សហគមន៍ NGO មានការសោកស្តាយចំពោះសភាជាតិដែលខ្វះកូរ៉ុម ដើម្បីអនុម័តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ នៅឆ្នាំ ២០០៣។ អំពើហិង្សាក្នុងគ្រួសារ ប៉ះពាល់ដល់ស្ត្រីកម្ពុជាប្រមាណ ២៥% ហើយកម្រនឹងមានការដាក់ទោសណាស់ សូម្បីតែនៅពេលដែលស្ត្រីទទួលរងរបួសធ្ងន់ធ្ងរក៏ដោយ។

NGO ស្វាគមន៍នូវការបង្កើនកិច្ចសហប្រតិបត្តិការជាមួយ NGO ពាក់ព័ន្ធនឹងការប្រឆាំងនឹងការជួញដូរ**ស្ត្រី និងកុមារ**។ ការបង្កើតនូវកិច្ចសហប្រតិបត្តិការកាន់តែខ្លាំង បានធ្វើអោយប្រសើរឡើងនូវការអនុវត្តច្បាប់។ ប្រការនេះត្រូវបន្ត និងពង្រឹង ជាពិសេសនៅថ្នាក់ខេត្ត។

កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីអនុវត្តនូវអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិរបស់កុមារ ត្រូវបានទទួលស្គាល់ដោយ NGO។ ទោះជាយ៉ាងនេះក្តី បញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹង**សិទ្ធិកុមារ** រួមមានពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ និងយុត្តិធម៌សំរាប់មនុស្សជំទង់ នៅតែបន្តកើតមាន និងទាមទារអោយមានវិធានការបន្ថែមទៀត។

មានភ័ស្តុតាងជាច្រើនដែលបង្ហាញថា **ការប្រើប្រាស់ថ្នាំញៀនក្នុងចំណោមកុមារ** គឺជាបញ្ហាដែលកំពុងតែកើនឡើង។ នេះគឺជាបញ្ហាដែលជាកង្វល់ដ៏ធ្ងន់ធ្ងរ ដោយហេតុថាការប្រើគ្រឿងញៀន រួមចំណែកដល់ការបង្កើតវិស័យមួយដែលប្រជាជនងាយរងគ្រោះថ្នាក់បញ្ហាដែលពាក់ព័ន្ធនឹងភាពក្រីក្រ ដូចជា ការកើនឡើងនូវបទឧក្រិដ្ឋ និងការបាត់បង់ឱកាសសិក្សា និងការងារ។ រហូតមកដល់ពេលនេះ ផលប៉ះពាល់ធ្ងន់ធ្ងរចំពោះការកើនឡើងនូវការប្រើប្រាស់គ្រឿងញៀន ក្នុងចំណោមក្មេងៗ ប្រហែលជាមិនត្រូវបានវាយតំលៃអោយបានពេញលេញ ពីអ្នកពាក់ព័ន្ធទាំងអស់នៅកម្ពុជាឡើយ។

NPRS ក៏មាននិយាយតិចតួចចំពោះ **មនុស្សចាស់**។ សកម្មភាពអភិវឌ្ឍន៍ទាំងឡាយ មិនទំនងជាមានផលវិបាកជាវិជ្ជមានលើមនុស្សចាស់ឡើយ ប្រសិនបើគំរោងទាំងនេះនៅតែត្រូវបានដកចេញ និង/ឬ មិនទទួលស្គាល់នៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ និងផលចំណេញ។

**HIV/AIDS** កំពុងជំរុញគ្រួសារជាច្រើន អោយធ្លាក់ទៅក្នុងភាពក្រីក្រ។ ទន្ទឹមនឹងមានការងារជាច្រើន ត្រូវបានធ្វើឡើងដើម្បីអប់រំប្រជាជន អំពី HIV/AIDS នៅតែមានតំរូវការ ដើម្បីធានាថា យុទ្ធសាស្ត្របញ្ចូលគ្នាមួយប្រកបដោយប្រសិទ្ធភាព ត្រូវបានអនុវត្ត។ ការយល់ដឹងអំពីជំងឺអេដស៍ ត្រូវប្រែក្លាយអោយទៅជាការកែប្រែអាកប្បកិរិយាក្នុងចំណោមប្រជាជនទាំងអស់។ នេះនឹងមិនត្រឹមតែពាក់ព័ន្ធ

នឹងការបន្តការអប់រំអំពី HIV/AIDប៉ុណ្ណោះទេ តែថែមទាំងការកសាងនូវការអប់រំមួយ ដែលផ្តោតលើប្រជាពលរដ្ឋទូទៅ ពាក់ព័ន្ធនឹងអាកប្បកិរិយាដែលមានការទទួលខុសត្រូវចំពោះផ្លូវភេទ និងកង្វល់ពីយែនឌ័រ។ សេវាគាំពារដែលមានប្រសិទ្ធភាព ត្រូវផ្តល់ជូនដល់អ្នកដែលឆ្លងជំងឺ HIV AIDS ដែលរួមមានការធានាអោយមានថ្នាំសង្កូវ ការអនុវត្តនៅទូទាំងប្រទេស នូវគោលនយោបាយបង្កាជំងឺពីម្តាយទៅកូន (PMCT) និងការកសាងនូវគោលនយោបាយថ្នាក់ជាតិ អំពីថ្នាំប្រឆាំងនឹងជំងឺឆ្លង។ ចំពោះអ្នកដែលឆ្លងជំងឺ HIV AIDS រួមមានកុមារ និងសមាជិកគ្រួសារទាំងមូល នៅតែមានឧបសគ្គចំពោះមុខក្នុងការកសាងគ្រួសារឡើងវិញ និង ការរកចំណូល។ ជាសំខាន់នោះគឺថា កម្ពុជាកសាងឡើងនូវ ការផ្តល់ប្រឹក្សា និងសេវាគាំទ្រចិត្តសាស្ត្រអោយកាន់តែប្រសើរ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់គ្រួសារ និងសហគមន៍ដែលឆ្លងជំងឺ HIVAIDS។

NPRS ទទួលស្គាល់ថា បច្ចុប្បន្ននេះ រដ្ឋាភិបាលខ្វះខាតយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព ដើម្បីគាំទ្រដល់សិទ្ធិរបស់ជនជាតិដើមភាគតិច។ សហគមន៍ NGO ស្វាគមន៍នូវបញ្ញត្តិទាំងឡាយនៅក្នុងច្បាប់ស្តីពីដីធ្លី ដែលអនុញ្ញាតអោយ **សហគមន៍ជនជាតិដើម** ស្នើសុំប័ណ្ណកម្មសិទ្ធិដីរបស់ខ្លួន នៅថ្នាក់ឃុំ។ ការកសាងឡើងនូវគំរោងផ្តល់ប័ណ្ណកម្មសិទ្ធិដីគំរូថ្នាក់ឃុំ កំពុងត្រូវបានតាមដានត្រួតពិនិត្យយ៉ាងជិតស្និទ្ធ ពីសំណាក់ NGO។ តែទោះជាយ៉ាងនេះក្តី ក្តីកង្វល់នៅតែកើតមានឡើងជុំវិញសម្បទានដី ដែលនាំអោយមានការធ្វើចំការកសិឧស្សាហកម្ម ក្នុងតំបន់ទាំងឡាយដែលជាព្រៃរបស់ជនជាតិដើមរស់នៅ និងកាត់បន្ថយការទទួលបានរបស់ជនជាតិដើម នូវធនធានធម្មជាតិរបស់ពួកគេ ដែលនាំអោយមានភាពក្រីក្រនៅក្នុងសហគមន៍ទាំងនេះ។

និយាយជាទូទៅ នៅពេលអនុវត្តគំរោងនៅក្នុងតំបន់ដែលមានជនជាតិដើមរស់នៅ ជាការសំខាន់នោះគឺថាប្រជាជនទាំងនេះមានឱកាសធ្វើសេចក្តីសំរេចចិត្ត អំពីអនាគតរបស់ពួកគេ។

វិមជ្ឈការដែលមានប្រសិទ្ធភាព ទាមទារនូវការប្តេជ្ញាចិត្តជាប់ជានិច្ច ក្នុងការគាំទ្រសហគមន៍ និងការអភិវឌ្ឍន៍ធនធានមនុស្ស និងចៀសវាងនូវការបង្កើតនូវវប្បធម៌ដែលពឹងផ្អែកលើគេ។

ជំពូកស្តីពីភាពងាយរងគ្រោះថ្នាក់ របស់ NPRS មានការយកចិត្តទុកដាក់តិចតួច ចំពោះ **ជនពិការ** ដែលជាក្រុមជនងាយរងគ្រោះ និងស្ថិតនៅឆ្ងាយពីសង្គមកម្ពុជាខ្ពស់បំផុត។ តែទោះជាយ៉ាងនេះក្តី ម៉ាទ្រីសនៃផែនការសកម្មភាព NPRS ស្នើអោយមានការគាំទ្រអោយកាន់តែប្រសើរឡើង ចំពោះជនពិការ។ នៅកម្ពុជា នៅមិនទាន់មាននិយមន័យច្បាស់លាស់អំពី " ពិការភាព" នៅឡើយ។ ទិន្នន័យផ្លូវការ មិនអាចគួរអោយជឿបាន និងនិយាយបន្ទាបចំនួនជនពិការ។ NPRS ក៏និយាយតិចតួចអំពីជំងឺខួរក្បាល និងពិការភាពក្នុងការរៀនសូត្រ។ ជាការសំខាន់នោះគឺ ទាំង RGC និងម្ចាស់ជំនួយទទួលស្គាល់ពិការភាព និងការធ្វើនីតិសម្បទា ថាជាបញ្ហាកាត់បន្ថយភាពក្រីក្រដ៏មានសារៈសំខាន់ និងចាត់វិធានការអោយបានខ្លាំងក្លា ដើម្បីបង្កើនការគាំទ្រទាំងទៅលើធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ កម្ពុជាបានទទួលរងគ្រោះពីទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលមានឥទ្ធិពលយ៉ាងខ្លាំង លើសហគមន៍ដែលងាយរងគ្រោះ។ NPRS ទទួលស្គាល់ថា**ការគ្រប់គ្រងគ្រោះមហន្តរាយ** គឺជាអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ សហគមន៍ NGO ស្វាគមន៍ការផ្តោតការយកចិត្តទុកដាក់នេះ និងរាល់កិច្ចខិតខំប្រឹងប្រែងរបស់ RGC និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីពង្រឹងការ

គ្រប់គ្រងគ្រោះមហន្តរាយ។ ទោះជាយ៉ាងនេះក្តី តំរូវអោយយុទ្ធសាស្ត្រ ច្បាស់លាស់សំរាប់ការត្រៀមទប់ទល់គ្រោះមហន្តរាយ ការជួយសង្គ្រោះ ការកាត់បន្ថយ និងការស្តារនីតិសម្បទា។ ប្រព័ន្ធផ្តល់ពត៌មានជាមុន និងចែកចាយពត៌មាន ទាមទារអោយមានការកែលំអរ។ ការត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ នៅថ្នាក់ភូមិ និងថ្នាក់ឃុំ ទាមទារអោយមានការគាំទ្រហិរញ្ញវត្ថុ គណនេយ្យភាពអោយកាន់តែប្រសើរ។

ការអភិវឌ្ឍន៍តំបន់ទីក្រុង ផ្លូវទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ជាទូទៅត្រូវបានទទួលស្វាគមន៍ ប៉ុន្តែអាចនាំទៅដល់ភាពក្រីក្រ សំរាប់សហគមន៍ដែលងាយរងគ្រោះ ដែលប្រឈមមុខនឹង**ការរុះរើទីលំនៅដោយបង្ខំ**។ បច្ចុប្បន្ននេះ មានកង្វះផ្នែកច្បាប់ ឬគោលនយោបាយជាតិ ដើម្បីការពារសិទ្ធរបស់ប្រជាជន ដែលប្រឈមមុខនឹងការរុះរើទីលំនៅ។

ជាចុងក្រោយ គួរកត់សំគាល់ថា **ការបន្តមានអាវុធតូច** មានផលវិបាកដែលបង្កជាឧបសគ្គមកលើសហគមន៍ដែលងាយរងគ្រោះថ្នាក់ ដោយបន្ថែមនូវអសន្តិសុខ និងវប្បធម៌នៃអំពើហិង្សា និងនីរទណ្ឌភាព។ សហគមន៍ NGO ទទួលស្គាល់នូវវិធានការ ដែល RGC បានធ្វើរួចមកហើយ ក្នុងការប្រមូល និងបំផ្លាញអាវុធខុសច្បាប់ជាច្រើនដើម។ ក៏ប៉ុន្តែ អាវុធនៅតែត្រូវបានប្រើប្រាស់ក្នុងរូបភាពជាច្រើន ដែលគំរាមកំហែងដល់សន្តិសុខ និងសុខុមាលភាពរបស់អ្នកក្រ ការទន្ទ្រានយកដី និងការបំភិតបំភ័យ។

### ៣.៦.៣. អនុសាសន៍

សហគមន៍ NGO ស្នើនូវអនុសាសន៍ដូចខាងក្រោម ពាក់ព័ន្ធនឹងក្រុមដែលងាយរងគ្រោះថ្នាក់ :

- ម្ចាស់ជំនួយគួរពិចារណាបង្កើនការគាំទ្ររបស់ខ្លួន ចំពោះវិស័យដូចជា ការការពារកុមារ សិទ្ធិរបស់ស្ត្រី ពិការភាព និងជនជាតិភាគតិច។ នេះគួរបំពេញបន្ថែម ដោយការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីពង្រឹងសមត្ថភាព និងវិភាជន៍ថវិកា របស់ក្រសួងពាក់ព័ន្ធ។
- ចាំបាច់ត្រូវជំរុញអោយមានការស្រាវជ្រាវបន្ថែម លើការប្រើប្រាស់គ្រឿងញៀន ជាពិសេសក្នុងចំណោមកុមារ ហើយគួរកសាងយុទ្ធនាការថ្នាក់ជាតិមួយ ដើម្បីអប់រំប្រជាជនអំពីគ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងញៀន។
- RGC ត្រូវកសាងនូវទិន្នន័យជាផ្នែកៗ ពាក់ព័ន្ធនឹងយែនឌ័រ នៅក្នុងគ្រប់វិស័យទាំងអស់ ដែលនឹងត្រូវផ្សព្វផ្សាយទៅដល់ ដើម្បីផ្តល់នូវសូចនាករ ដ៏មានសារៈប្រយោជន៍ផ្នែកយែនឌ័រ និងបង្ហាញពីកំរិតតំរូវការជាក់លាក់របស់ស្ត្រី និងការចូលរួមចំណែកចំពោះសង្គម។ មានការចាំបាច់ផងដែរ ចំពោះការកែលំអទិន្នន័យស្តីពីក្រុមពលរដ្ឋងាយរងគ្រោះ ដូចជាជនជាតិភាគតិច និងពលរដ្ឋដែល មានពិការភាព
- សភាជាតិចាំបាច់ត្រូវពិនិត្យយ៉ាងម៉ត់ចត់ និងអនុម័តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ធ្វើជាការងារអាទិភាព។ បន្ទាប់ពីនេះ នឹងមានភាពចាំបាច់ក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព
- RGC គួរចាត់វិធានការដើម្បីអនុម័តយក " គោលនយោបាយទូទៅសំរាប់ការអភិវឌ្ឍន៍ប្រជាជន នៅតំបន់ភ្នំ "។ កម្ពុជាត្រូវការនូវគោលនយោបាយជាតិមួយ ដែលនឹងអនុញ្ញាតអោយជនជាតិដើម ដឹកនាំការអភិវឌ្ឍន៍របស់ពួកគេ
- សេចក្តីព្រាងច្បាប់ស្តីពីពិការភាព ត្រូវអនុម័ត ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ជនពិការ។
- ទាមទារអោយមានផែនការរយៈពេលវែង សំរាប់វិស័យពិការភាព ដោយធានានូវការប្តេជ្ញាចិត្តផ្តល់

ហិរញ្ញវត្ថុគ្រប់គ្រាន់ សំរាប់សេវានីតិសម្បទា លទ្ធភាព ទទួលយានសំរាប់ជនពិការ និងលទ្ធភាព ទទួលសេវា នានារបស់រដ្ឋាភិបាល។

- គប្បីរៀបចំ " គោលនយោបាយជាតិស្តីពីការតាំង ទីលំនៅសារជាថ្មី "តាមរយៈដំណើរការដែលមានការ ចូលរួម ដើម្បីការពារសិទ្ធិរបស់ពលរដ្ឋ ដែលរងគ្រោះ ដោយសារគំរោងនេះ។ បន្ទាប់មក រាជរដ្ឋាភិបាល កម្ពុជាគប្បីអនុម័តគោលនយោបាយ នេះតាមរយៈ អនុក្រឹត្យមួយ ហើយបន្ទាប់មក ចេញសេចក្តីប្រកាស សំរាប់អនុវត្តគោលនយោយនេះ ដែលមានស្តង់ដារ ប្រើប្រាស់ចំពោះ រាល់គំរោងទាំងអស់។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តច្បាប់ និងនីតិវិធីដែលមានស្រាប់ ដើម្បី ធានាអោយមានតម្លាភាព និងការការពារ និងការប៉ះ ប៉ូវសំណង សមស្របចំពោះប្រជាជនដែល ទទួលរង ការប៉ះពាល់។ គប្បីផ្តល់លទ្ធភាព ផងដែរចំពោះប្រជា ពលរដ្ឋនូវលទ្ធភាព ទទួលពតិមាននិងគប្បីផ្តល់ លទ្ធភាពអោយពលរដ្ឋទាំងនោះចូលរួមក្នុងការរៀបចំ គំរោងដែលប៉ះពាល់ចំពោះពួកគេ។
- សភាជាតិត្រូវអនុម័តច្បាប់អាវុធ និងអនុវត្តអោយ បានតឹងរ៉ឹងនូវបទប្បញ្ញត្តិនៃច្បាប់នេះ ដើម្បីធានានូវ ការដកអាវុធខុសច្បាប់បន្ថែមទៀត ពីសង្គមកម្ពុជា។ ទន្ទឹមនឹងនេះ NRGC គួរចាត់ វិធានការអោយកាន់តែ មានប្រសិទ្ធភាព ដើម្បី ធានាសន្តិសុខសំរាប់សហគមន៍ មូលដ្ឋាន ជាពិសេស អ្នកទាំងឡាយណាដែលងាយ រងគ្រោះ ចំពោះបញ្ហាសន្តិសុខខ្លាំងបំផុត។ ចាំបាច់ ត្រូវដាក់អោយ អនុវត្តនូវបទប្បញ្ញត្តិដែលមានស្រាប់ ទាក់ទងនឹងអាវុធយុទ្ធភ័ណ្ឌ។
- នគរបាល និងតុលាការគប្បីធានាអោយអ្នកដែល ត្រូវ បានឃាត់ខ្លួន ចំពោះឥរិយាបទឧក្រិដ្ឋមិនត្រូវបានដោះ លែង ដោយសារការបង់ប្រាក់ប៉ះប៉ូវអោយជន រងគ្រោះ។